មហាសន្និបាត

ចែកចាយៈ ទូទៅ
ថ្ងៃទី៧ កញ្ញា ២០១៨

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីសាមសិបប្រាំបួន**
ថ្ងៃទី១០-២៨ ខែកញ្ញា ឆ្នាំ២០១៨
របៀបវារៈ ចំណុចទី ១០
**ជំនួយផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

# របាយការណ៍អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

សេចក្តីបន្ថែមទៅលើរបាយការណ៍ប្រចាំឆ្នាំ(A/HRC/39/73)នេះ ផ្តោតទៅលើបញ្ហាសិទ្ធិមនុស្សនានា ដែលឆ្ពោះទៅកាន់ការបោះឆ្នោតនិងក្នុងអំឡុងពេលដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨។ ក្នុងអំឡុងពេលនៃការពិភាក្សាអន្តរកម្មនៅក្នុងសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សលើកទី៣៦ រដ្ឋជាច្រើន បានស្នើឲ្យអ្នករាយការណ៍ពិសេស ផ្តោតការចាប់អារម្មណ៍ជាពិសេសទៅលើផលប៉ះពាល់សិទ្ធិមនុស្សនៃស្ថានភាពនយោបាយ មុនការបោះឆ្នោតថ្នាក់ជាតិ។ ដោយសារតែរបាយការណ៍ប្រចាំឆ្នាំ ត្រូវដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស មុនការបោះឆ្នោតដែលត្រូវរៀបចំឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨នោះ សេចក្តីបន្ថែមនេះ បានព្យាយាមវិភាគទៅលើស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលបោះឆ្នោត ក៏ដូចជាផលប៉ះពាល់ដែលកើតចេញពីការបោះឆ្នោតនោះ។

សេចក្តីបន្ថែមនេះ ដាក់បញ្ចូលព័ត៌មានរហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ នៅពេលដែលលទ្ធផលបោះឆ្នោតផ្លូវការត្រូវបានប្រកាស។ ក្តីបារម្ភជាច្រើនទាក់ទងនឹងច្បាប់និងករណីបុគ្គល ធ្លាប់ត្រូវបានលើកឡើងទៅកាន់រដ្ឋាភិបាលកម្ពុជា នៅក្នុងការប្រាស្រ័យទាក់ទងគ្នាពីមុនៗរួចហើយ។ សេចក្តីព្រាងនៃសេចក្តីបន្ថែមនេះ បានចែកជូនរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី២០ ខែសីហា។

សេចក្តីបន្ថែមនេះ ដាក់បញ្ចូលព័ត៌មានដែលអ្នករាយការណ៍ពិសេសបានទទួលអំពីករណីជាក់លាក់ និងការចោទប្រកាន់ទៅលើការរំលោភបំពានសិទ្ធិមនុស្ស។ ឈ្មោះមួយចំនួន និងព័ត៌មានលម្អិតអំពីអត្តសញ្ញាណផ្ទាល់ខ្លួនមួយចំនួនមិនត្រូវបានបង្ហាញ ពីព្រោះការបញ្ចេញព័ត៌មានទាំងនេះអាចធ្វើឲ្យប្រភពព័ត៌មានជួបហានិភ័យ។ ព័ត៌មានលម្អិតរបស់ប្រភពត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍នេះ តែក្នុងករណីដែលប្រភពព័ត៌មានបានព្រមព្រៀងផ្ទាល់មាត់ដោយមានការជូនដំណឹងគ្រប់គ្រាន់ច្បាស់លាស់អំពីការប្រើប្រាស់ព័ត៌មាន

ទៅប្រភពពត៌មាន ។ មានតែព័ត៌មានដែលចាត់ទុកថា អាចជឿ និងទុកចិត្តបាន ប៉ុណ្ណោះដែលត្រូវបានដាក់បញ្ចូល។ នៅកន្លែងខ្លះ តាមដែលអាចធ្វើទៅបាន ព័ត៌មាននោះត្រូវបានបញ្ជាក់ឲ្យកាន់តែច្បាស់តាមរយៈប្រភពផ្សេងទៀត។ ប្រភពព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយសង្គមនិងព័ត៌មានអនឡាញ ក៏ត្រូវបានដាក់បញ្ចូលដែរ ដោយសារតែការប្រើប្រាស់នេះ មានការរីកសាយភាពខ្លាំងនៅក្នុងបរិបទប្រទេសកម្ពុជា ហើយប្រព័ន្ធផ្សព្វផ្សាយបែបនេះ ត្រូវបានអាជ្ញាធរកម្ពុជាប្រើជាទូទៅក្នុងការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍របស់ខ្លួនដែរ។

# I. សិទ្ធិទទួលបានការចូលរួមក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

1. ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ហើយត្រូវដាក់របាយការណ៍លើកទីបី ជូនទៅគណៈកម្មាធិការសិទ្ធិមនុស្សនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩។ មាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ទទួលស្គាល់និងការពារសិទ្ធិរបស់ពលរដ្ឋគ្រប់រូប ដោយគ្មានការរើសអើង ឬការរឹតត្បឹតដោយមិនសមហេតុផលណាមួយឡើយ ក្នុងការចូលរួមធ្វើកិច្ចការសាធារណៈ ក្នុងការបោះឆ្នោត និងក្នុងការឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ ព្រមទាំងចូលបម្រើមុខងារសាធារណៈដោយស្មើភាពគ្នានៅក្នុងប្រទេស។ ប្រការនេះ ជាចំណុចស្នូលនៃរដ្ឋាភិបាលប្រជាធិបតេយ្យដែលផ្អែកទៅលើការយល់ព្រមពីប្រជាជន[1] និងត្រូវបានទទួលស្គាល់នៅក្នុងឧបករណ៍អន្តរជាតិដទៃទៀតដែរ។[2] វាជាផ្នែកដ៏សំខាន់មួយនៃរបៀបវារៈឆ្នាំ២០៣០ស្តីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៦។[3]

2. ទោះបីជាមាត្រា២៥ បង្កើតនូវស្នូលនៃ "សិទ្ធិនយោបាយ" នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិក៏ដោយ ក៏គេមិនអាចមើលទៅលើមាត្រានេះតែឯងដាច់ដោយឡែកពីគេឡើយ។ ការសម្រេចបានសិទ្ធិនេះ ទាមទារឲ្យមានបរិយាកាសអំណោយផលមួយ ដែលមានការគោរពទៅលើសិទ្ធិដទៃទៀតផងដែរ។ សិទ្ធិទាំងនោះ រួមមាន សិទ្ធិទទួលបានសមភាពនិងការមិនរើសអើង និងសិទ្ធិទទួលបានការអប់រំ ក៏ដូចជាសេរីភាពមូលដ្ឋានក្នុងការសម្តែងទស្សនៈនិងបញ្ចេញមតិ ការប្រមូលផ្តុំដោយសន្តិវិធី និងសមាគម។[4]

3. ការបោះឆ្នោតជាលក្ខណ្ឌដ៏សំខាន់មួយក្នុងប្រព័ន្ធប្រជាធិបតេយ្យ។ មាត្រា២៥(ខ) ផ្តោតលើសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត នៅក្នុងការបោះឆ្នោតដ៏ពិតប្រាកដតាមកាលកំណត់ តាមរយៈសិទ្ធិបោះឆ្នោតជាសាកលនិងស្មើភាពគ្នា និងតាមរយៈសន្លឹកឆ្នោតសម្ងាត់។ វាមិនមានការកំណត់អំពីប្រព័ន្ធបោះឆ្នោតជាក់លាក់ណាមួយនោះទេ ហើយវាជាបញ្ហារបស់ច្បាប់ជាតិនិងអធិតេយ្យជាតិ នោះ ប៉ុន្តែ ការបោះឆ្នោតណាក៏ដោយត្រូវតែធានាឲ្យអ្នកបោះឆ្នោតបញ្ចេញឆន្ទៈរបស់ខ្លួនដោយសេរី។[5] ទោះបីជារដ្ឋ អាចដាក់ចេញនូវលក្ខខណ្ឌឬការរឹតត្បឹតក៏ដោយ ក៏វាត្រូវតែផ្អែកទៅលើលក្ខណៈវិនិច្ឆ័យសមហេតុផលនិងច្បាស់លាស់។[6] ឧទាហរណ៍ គណៈកម្មាធិការសិទ្ធិមនុស្ស បានចង្អុលបង្ហាញថា ការរឹតត្បឹតដែលសមហេតុសមផល រួមមានដូចជា ការកំណត់អាយុអប្បបរមា ប៉ុន្តែការរឹតត្បឹតណាមួយទៅលើពិការភាពរាងកាយ ឬលក្ខខណ្ឌតម្រូវអំពីអក្ខរភាព កម្រិតអប់រំ ឬកម្រិត

[1] សេចក្តីពន្យល់ទូទៅលេខ ២៥ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ, CCPR/C/Rev.1/Add.7

[2] See e.g. CEDAW, articles 7 and 8; CRPD, articles 4(3), 29 and 33(3)

[3] See e.g. Targets 16.7 and 16.10 of SDG 16

[4] CCPR General Comment no.34, CCPR/C/GC/34, para 4 and 20

[5] CCPR/C/Rev.1/Add.7, para 21

[6] CCPR/C/Rev.1/Add.7, para 4

ទ្រព្យសម្បត្តិ គឺជាការរើតត្បឹតមិនសមហេតុផលឡើយ។[7] មាត្រា២៥នោះគ្របដណ្តប់តែពលរដ្ឋប៉ុណ្ណោះ ដូចនេះ បទប្បញ្ញត្តិអំពីភាពជាពលរដ្ឋ មិនគួរមានលក្ខណៈរើសអើងឡើយ។[8]

4. គំនិតអំពីការបញ្ចេញមតិដោយសេរីតាមឆន្ទៈរបស់អ្នកមានសិទ្ធិបោះឆ្នោត មិនកំហិតត្រឹមតែពេលគូសសន្លឹកឆ្នោតតែមួយពេលនោះទេ។ ដើម្បីឲ្យការបោះឆ្នោតមានភាពត្រឹមត្រូវពិតប្រាកដ និងធានាបាននូវឆន្ទៈរបស់អ្នកបោះឆ្នោត ការបោះឆ្នោតនោះត្រូវរៀបចំឡើងនៅកន្លែងដែលមនុស្សគ្រប់រូបទទួលបានសិទ្ធិមនុស្សដោយរីករាយ ជាពិសេស ដោយមានការគោរពសិទ្ធិរស់រានមានជីវិត សុចរិតភាពផ្លូវកាយនិងផ្លូវចិត្ត សេរីភាព សុវត្ថិភាព និងឯកជនភាព។ ជាងនេះទៀត ដើម្បីធានាឲ្យមានការប្រកួតប្រជែងស្មើភាពគ្នា សេរីភាពសម្តែងទស្សនៈនិងបញ្ចេញមតិ ការប្រមូលផ្តុំដោយសន្តិវិធី និងសមាគម ត្រូវតែធានាឲ្យមាន។ គណៈកម្មាធិការសិទ្ធិមនុស្ស ក៏បានកត់សម្គាល់អំពីសារៈសំខាន់នៃ "ការប្រកួតប្រជែងពិតប្រាកដ" និងអំពាវនាវឲ្យមានវប្បធម៌ពហុនិយមផ្នែកនយោបាយនិងការជជែកដេញដោលនយោបាយពហុភាព។[9]

5. ការបោះឆ្នោត ត្រូវតែធ្វើឡើងដោយសេរីនិងយុត្តិធម៌ ដោយអ្នកមានសិទ្ធិបោះឆ្នោតមានសេរីភាពក្នុងការបោះឆ្នោតជ្រើសរើសបេក្ខជនណាក៏បាន ដោយគ្មានការជះឥទ្ធិពលឬការបង្ខំគ្រប់ប្រភេទ។[10] នៅទីណាដែលការបោះឆ្នោត មិនមែនជាកាតព្វកិច្ច អ្នកបោះឆ្នោតអាចមិនទៅបោះឆ្នោត ឬ ធ្វើពហិកាមិនបោះឆ្នោត។[11] ការប្រាស្រ័យទាក់ទងព័ត៌មានដោយសេរីរវាងពលរដ្ឋ បេក្ខជន និងតំណាងជាប់ឆ្នោត មានសារៈសំខាន់ណាស់ តាមរយៈការមើលឃើញថា ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យអាចប្រតិបត្តិការបានដោយគ្មានការពិនិត្យត្រួតត្រាឬការដាក់កំហិត។[12] អ្នកការពារសិទ្ធិ និងសង្គមស៊ីវិលដែលសកម្ម ជារឿយៗមានអំណោយផលសម្រាប់ការបោះឆ្នោតត្រឹមត្រូវពិតប្រាកដ ជាពិសេស ពួកគេក៏ជួយជ្រោមជ្រែងដល់អ្នកបោះឆ្នោត ក្នុងការបង្កើតទស្សនៈឯករាជ្យ ដែលជារឿយៗមានការតវ៉ាសួរដេញដោលជាមួយអ្នកមានអំណាច។ ជាតុផ្សំសំខាន់ៗផ្សេងទៀត រួមមាន អាជ្ញាធររៀបចំការបោះឆ្នោតឯករាជ្យ ដើម្បីធានាថា ការបោះឆ្នោតមិនមានភាពលម្អៀង និងយោងតាមច្បាប់ជាតិ ដែលមានសង្គតិភាពជាមួយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជាមានការពិនិត្យពិច័យនិងការពិនិត្យឡើងវិញទៅលើការតុលាការដោយឯករាជ្យ។[13]

## II. ការបោះឆ្នោតពីឆ្នាំ១៩៩៣ ដល់ ២០១៣

6. បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសមក ប្រទេសកម្ពុជាបានរៀបចំការបោះ

---

[7] CCPR/C/Rev.1/Add.7, para 10

[8] CCPR/C/Rev.1/Add.7, para 3

[9] For example, see CCPR/C/UZB/CO/4 (2015), Para 26

[10] CCPR/C/Rev.1/Add.7, para 19

[11] General Comment no. 34, CCPR/C/GC/34, para 28

[12] CCPR/C/Rev.1/Add.7, para 25 ; see also E/CN.4/1998/40, para 24

[13] CCPR/C/Rev.1/Add.7, para 20

ឆ្នោតសភាជាតិ ចំនួនប្រាំដង មុនការមកដល់នៃការបោះឆ្នោតខែកក្កដា ឆ្នាំ២០១៨ នេះ (សូមមើលក្រាហ្វិចលេខ១ នៅទំព័រ៣៦)។ ប្រទេសកម្ពុជា ក៏បានរៀបចំការបោះឆ្នោត អសាកលដើម្បីជ្រើសរើសសមាជិកព្រឹទ្ធសភា ក៏ដូចជាការបោះឆ្នោតមូលដ្ឋានដើម្បីជ្រើសរើសមន្ត្រីថ្នាក់ឃុំសង្កាត់និងស្រុកខណ្ឌដែរ។ ទោះបីជាវាហាក់ដូចជាមានការកែលម្អជាទូទៅក្នុងការរៀបចំការបោះឆ្នោតក៏ដោយ ក៏ការងាររបស់អ្នកកាន់អាណត្តិនីតិវិធីពិសេសមុនៗ បង្ហាញថា ក្តីបារម្ភអំពីបញ្ហាសិទ្ធិមនុស្សទាក់ទងនឹងការបោះឆ្នោតនិងការចូលរួមផ្នែកនយោបាយ មិនមានការប្រែប្រួលឡើយ។

7. ជាពិសេស អ្នកកាន់អាណត្តិមុនៗខ្ញុំ បានធ្វើការកត់សម្គាល់ដោយស៊ីសង្វាក់គ្នា អំពីក្តីបារម្ភមុនៗ ជុំវិញបញ្ហាសេរីភាពបញ្ចេញមតិនិងការបំភិតបំភ័យសកម្មជននយោបាយនិងអ្នកបោះឆ្នោត។[14] អ្នកកាន់អាណត្តិមុនម្នាក់ បានរំលេចឡើងថា ការរឹតត្បិតនិងការបំភិតបំភ័យបែបនេះ បណ្តាលឲ្យមានឥទ្ធិពលគួរឲ្យភ័យខ្លាចទៅលើសេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា ដោយមានប្រជាជនកម្ពុជាជាច្រើន បានដាក់កម្រិតសេរីភាពខ្លួនឯង នៅពេលដែលពួកគេនិយាយឬសរសេរ ដោយភ័យខ្លាចមានការចាប់ខ្លួននិងការឃុំខ្លួន ប្រសិនបើពួកគេបញ្ចេញទស្សនៈដែលមានការរិះគន់ទៅដល់អ្នកមានអំណាច។[15] បន្ថែមលើនេះ ទាក់ទងនឹងការបោះឆ្នោតឆ្នាំ២០០៨ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានរកឃើញថាមាន "យុទ្ធនាការយ៉ាងច្បាស់ ក្នុងការគាបសង្កត់ គំរាមកំហែង បំភិតបំភ័យ និងការទិញទឹកចិត្ត ដោយផ្ទាល់ទៅលើសកម្មជននយោបាយនៅគ្រប់កម្រិត ក្នុងគោលបំណងអូសទាញពួកគេឲ្យផ្លាស់ប្តូរគណបក្ស"។[16] សេចក្តីថ្លែងការណ៍ ក៏បានកត់សម្គាល់អំពីវិសមភាពដែលបានចាក់ចូលយ៉ាងជ្រៅក្នុងចំណោមគណបក្សនយោបាយ ទាក់ទងនឹងការទទួលបាន និងការត្រួតត្រាទៅលើប្រព័ន្ធផ្សព្វផ្សាយ។ ក្នុងការបោះឆ្នោតឆ្នាំ២០១៣ ទោះបីប្រកបដោយសន្តិវិធីខ្លាំង នៅដំណាក់កាលមុនបោះឆ្នោតក៏ដោយ ក៏អ្នករាយការណ៍ពិសេសបានកត់សម្គាល់ថា យុទ្ធនាការបំភិតបំភ័យ និងគាបសង្កត់នៅតែមានភាពលើសលុប ជាពិសេសនៅក្នុងតំបន់ជនបទ។[17] អសមត្ថភាពឬភាពគ្មានឆន្ទៈរបស់ប្រព័ន្ធតុលាការក្នុងការឆ្លើយតបឲ្យបានសមស្របចំពោះបញ្ហាសេរីភាពបញ្ចេញមតិ ត្រូវបានកត់សម្គាល់ដដែលៗ[18] ដោយបានលើកឡើងនូវក្តីបារម្ភអំពីការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ[19] និងឯករាជ្យនៃប្រព័ន្ធតុលាការ។[20]

8. ក្តីបារម្ភដដែលៗផ្សេងទៀតដែលអ្នកកាន់អាណត្តិមុនខ្ញុំបានលើកឡើង រួមមានការដែលគណបក្សនយោបាយប្រើប្រាស់ធនធានរបស់រដ្ឋ រួមទាំងពេលវេលារបស់មន្ត្រីរដ្ឋាភិបា

[14] A/50/681, Para 47; A/HRC/21/63, paras 33-34; A/HRC/18/46, paras 18-19

[15] A/HRC/21/63 – paras 31, 55-57

[16] https://cambodia.OHCHR.org/~cambodiaOHCHR/sites/default/files/news/WebDOCs/2008/Statement_29072008E.pdf

[17] A/HRC/24/36, para 35

[18] A/HRC/18/46, 18-19; A/HRC/21/63, para 34

[19] A/HRC/18/46, para 23 and A/HRC/24/36, para 44-45

[20] A/HRC/15/46

ល យានជំនិះ សម្ភារៈ និងយោធា ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត[21] កំហុសរបស់រដ្ឋសភា ដែលរួមមានទាំងការមិនការពារសេរីភាពសម្តែងមតិរបស់តំណាងរាស្ត្រ[22] និងការផ្តល់ឱកាសមិនគ្រប់គ្រាន់ សម្រាប់តំណាងរាស្ត្រគណបក្សប្រឆាំងក្នុងការជជែកវែកញែកសេចក្តីព្រាងច្បាប់ឲ្យមានប្រសិទ្ធភាព។[23] អ្នកកាន់អាណត្តិមុនខ្ញុំ ក៏បានរំលេចឡើងច្បាស់អំពីការប្រើប្រាស់ការចោទប្រកាន់បទបរិហារកេរ្តិ៍និងការផ្តល់ព័ត៌មានមិនពិត ដែលរដ្ឋាភិបាលឬតំណាងរដ្ឋាភិបាល បានប្តឹងទៅលើសមាជិកមួយចំនួនរបស់គណបក្សប្រឆាំង និងអ្នករិះគន់គោលនយោបាយ ឬការអនុវត្តសាធារណៈផ្សេងៗទៀត។[24] ក្តីបារម្ភជុំវិញការចាត់ទុកការប្រមាថនិងការបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ ត្រូវបានលើកឡើងតាំងពីឆ្នាំ១៩៩៤-៥ មកម្ល៉េះ។[25] ចំណុចនេះនៅតែជាបញ្ហា ដោយផ្អែកលើ មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។[26]

9. ក្តីបារម្ភសំខាន់មួយទៀត ដែលត្រូវបានលើកឡើងដដែលៗដែរនោះ គឺការរើសអើងទៅលើនិគមជនវៀតណាម។ ក្នុងឆ្នាំ១៩៩៨ តំណាងពិសេសរបស់អគ្គលេខាធិការនៅពេលនោះ បានចងក្រងឯកសារអំពីក្តីបារម្ភមួយចំនួនដែលមិនត្រឹមតែទាក់ទងនឹងការចុះបញ្ជីអត្តសញ្ញាណ (ដែលរួមមានការធ្វើតេស្តិ៍ភាសា បើទោះបីមានឯកសារអត្តសញ្ញាណ) ប៉ុន្តែគណបក្សប្រឆាំងនិងអ្នកនយោបាយខ្លះបានបញ្ចេញមតិ បែបរើសអើងនិងបង្កហេតុថែមទៀត។ ។របាយការណ៍នោះ បានកត់សម្គាល់ថា អ្នកនយោបាយគណបក្សប្រឆាំងខ្លះ បានធ្វើយុទ្ធនាការទៅលើប្រធានបទមួយទាក់ទងនឹងការស្អប់និគមជន។[27] ការសម្តែងវោហាស័ព្ទស្រដៀងគ្នាដែលមានលក្ខណៈប្រកាន់ពូជសាសន៍និងប្រឆាំងជនជាតិវៀតណាមនោះ ត្រូវបានប្រើដោយតំណាងគណបក្សនយោបាយជាច្រើនក្នុងអំឡុងយុទ្ធនាការឃោសនាបោះឆ្នោតឆ្នាំ២០០៣។ របាយការណ៍ឆ្នាំ២០០៣ ដោយតំណាងពិសេសរបស់អគ្គលេខាធិការ ក៏បានកត់សម្គាល់អំពីការធ្វើទុក្ខទោសខានដល់ជនជាតិកម្ពុជាដែលជាកូនចៅរបស់ជនជាតិវៀតណាម នៅថ្ងៃបោះឆ្នោតនិងក្រោយមកទៀតដែរ។[28] ក្តីបារម្ភស្រដៀងគ្នានេះ ក៏ត្រូវបានកត់សម្គាល់ដែរ ទាក់ទងនឹងការបោះឆ្នោតឆ្នាំ២០១៣។[29]

## III. ការបោះឆ្នោតជាតិឆ្នាំ២០១៣ និងក្រោយការបោះឆ្នោត

10. ការបោះឆ្នោតឆ្នាំ២០១៣ ផ្តល់នូវលទ្ធផលជ័យជំនះសម្រាប់គណបក្សប្រជាជនកម្ពុ

[21] A/HRC/21/63, para 52; A/HRC/24/36, para 38

[22] A/HRC/18/46

[23] A/HRC/15/46 Para 15; A/HRC/18/46

[24] A/HRC/12/40, para 19

[25] E/CN.4/1995/87, para 55 and A/50/681, para 45

[26] CCPR/C/KHM/CO/2, para 21. Also CCPR General Comment no.34, CCPR/C/GC/34, para 38 and 47

[27] A/53/400, paras 58-60

[28] A/58/317, para 22

[29] A/HRC/27/70, paras 52-3

ជា ដោយទទួលបានអាសនៈចំនួន៦៨ (៤៨,៨៣% នៃសន្លឹកឆ្នោតបានការ) ខណៈដែលគណបក្សប្រឆាំងចម្បងគឺគណបក្សសង្គ្រោះជាតិ ដែលពេលនោះទើបបានបង្កើតឡើង [30] ទទួលបាន ៥៥អាសនៈ (៤៤,៤៦%)។ ក៏ប៉ុន្តែ មានការចោទប្រកាន់ដែលអាចជឿជាក់បានអំពី "ភាពមិនប្រក្រតីធ្ងន់ធ្ងរក្នុងការបោះឆ្នោត"។[31] អ្នកកាន់អាណត្តិមុនខ្ញុំ បានសម្តែងនូវការខកចិត្តចំពោះការបរាជ័យរបស់រដ្ឋាភិបាល និងគណៈកម្មាធិការរៀបចំការបោះឆ្នោតដែលខកខានមិនបាន "សម្រួលឲ្យមានការស៊ើបអង្កេតភ្លាមៗ មិនលម្អៀង មានតម្លាភាពជឿជាក់បាន និងពេញលេញមួយ ទៅលើភាពមិនប្រក្រតីដែលបានចោទឡើងនោះ"។[32] ក៏ប៉ុន្តែ ការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងការបោះឆ្នោតនេះ គឺភស្តុតាងដែលបានលេចឡើងថាគណបក្សប្រឆាំងអាចប្រជែងយ៉ាងពិតប្រាកដជាមួយនឹងគណបក្សកាន់អំណាចក្នុងប្រទេសកម្ពុជា តាមរយៈមធ្យោបាយដោយសន្តិវិធី និងនៅទីបំផុត មានសក្តានុពលក្នុងការទទួលបានអំណាច។

11. គណបក្សសង្គ្រោះជាតិ បដិសេធមិនទទួលយកអាសនៈទាំងនោះនៅក្នុងរដ្ឋសភាដើម្បីជាការតវ៉ាចំពោះភាពមិនប្រក្រតីដែលបានអះអាងឡើងទាំងនោះ។ ការចោទប្រកាន់ដែលមានភាពស៊ីសង្វាក់គ្នាទៅនឹងការវិភាគរបស់ក្រុមសង្កេតការណ៍បោះឆ្នោត និងក្រុមសង្គមស៊ីវិលទាំងនោះ បានឈានទៅដល់ការតវ៉ាទូទាំងប្រទេស។[33] អ្នកធ្វើដំណើរតាមផ្លូវម្នាក់ ត្រូវបានគេបាញ់ស្លាប់នៅថ្ងៃទី១៥ ខែកញ្ញា[34] និងម្នាក់ទៀតនៅថ្ងៃទី១២ ខែវិច្ឆិកា នៅពេលដែលកម្លាំងសន្តិសុខបានបាញ់គ្រាប់ពិត បន្ទាប់ពីមានការប៉ះទង្គិចជាមួយអ្នកតវ៉ានៅទីក្រុងភ្នំពេញ។[35] ភាពតានតឹងបានកើនឡើងនៅចុងឆ្នាំ គឺនៅពេលដែលកម្មកររាប់ពាន់អ្នកចូលរួមធ្វើការតវ៉ាជាមួយការតវ៉ារបស់គណបក្សប្រឆាំង ហើយការប្រើប្រាស់កម្លាំងហួសហេតុដោយកងកម្លាំងសន្តិសុខ បានសម្លាប់បាតុករយ៉ាងហោចណាស់ចំនួនប្រាំនាក់ នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤។[36] នៅថ្ងៃបន្ទាប់ រដ្ឋាភិបាលបានហាមឃាត់រាល់ការធ្វើបាតុកម្ម ការដង្ហែក្បួន ឬការប្រមូលផ្តុំនានា ដោយសារមូលហេតុសណ្តាប់ធ្នាប់សាធារណៈនិងសន្តិសុខសាធារណៈ ដោយរួមទាំងមិនឲ្យមានការជួបជុំនៅទីលានប្រជាធិបតេយ្យ ដែលជាទីតាំងរៀបចំឡើងសម្រាប់ការតវ៉ាជាសាធារណៈនៅទីក្រុងភ្នំពេញដែរ។[37]

---

[30] ត្រូវបានបង្កើតឡើងបន្ទាប់អីការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០១២ តាមរយៈការបញ្ចូលគ្នារវាងគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស។

[31] A/HRC/24/36 para 39-40

[32] Oral statement at the HRC, September 2013, at https://cambodia.OHCHR.org/~cambodiaOHCHR/sites/default/files/news/WebDOCs/2013/SR_Cambodia_statement_ENG.pdf

[33] Oral statement at the HRC, Sep 2013, see FN 33; KHM 1/2013, https://spdb.OHCHR.org/hrdb/24th/Public_-_UA_Cambodia_01.10.13_(1.2013)_Pro.pdf

[34] ????

[35] https://newsarchive.OHCHR.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=13995&LangID= E

[36] A/HRC/27/70, para 13; KHM 2/2014, https://spdb.OHCHR.org/hrdb/25th/Public_-_UA_Cambodia_28.02.14_(2.2014)_Pro.pdf

[37] KHM 1/2014, https://spdb.OHCHR.org/hrdb/25th/public_-_AL_Cambodia_17.02.14_(1.2014).pdf

12. រដ្ឋាភិបាលនិងគណបក្សសង្គ្រោះជាតិ បានឈានដល់កិច្ចព្រមព្រៀងនយោបាយមួយ ក្នុងខែកក្កដា ឆ្នាំ២០១៤ ដែលបានបញ្ចប់ការទាមទាររបស់គណបក្សសង្គ្រោះជាតិសុំឲ្យមានការស៊ើបអង្កេតឯករាជ្យមួយទៅលើការបោះឆ្នោត ហើយជាលទ្ធផល រដ្ឋាភិបាលបានប្តេជ្ញាក្នុងការកែទម្រង់។ ជាចំណែកមួយនៃ "វប្បធម៌សន្ទនា" គណបក្សសង្គ្រោះជាតិ បានទទួលយកអាសនៈក្នុងរដ្ឋសភាក្នុងខែសីហា ឆ្នាំ២០១៤។ បន្ទាប់មក គ.ជ.ប ត្រូវបានកែប្រែឡើងវិញ ដោយមានតំណាងស្មើគ្នានៃគណបក្សទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា និងសមាជិកឯករាជ្យមួយរូប។[38]

13. ប៉ុន្តែ វប្បធម៌សន្ទនារវាងគណបក្សនយោបាយចម្បងទាំងពីរ មិននៅស្ថិតស្ថេរបានយូរនោះទេ។ ស្ថានភាពនយោបាយ បានក្លាយទៅជាមានសភាពអាក្រក់យ៉ាងឆាប់រហ័ស។ ក្នុងខែកក្កដា ឆ្នាំ២០១៥ សមាជិកនិងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ១១នាក់ ត្រូវបានផ្តន្ទាទោស និង៣នាក់ទៀតត្រូវបានចាប់ខ្លួនក្នុងខែសីហា ពីបទដឹកនាំឬចូលរួមក្នុង "ចលនាកុប្បកម្ម" បន្ទាប់ពីមានការប៉ុនប៉ងមិនបានសម្រេចកាលពីមួយឆ្នាំមុន ដើម្បីបើកសួនប្រជាធិបតេយ្យឡើងវិញសម្រាប់ការធ្វើបាតុកម្ម ដែលនៅក្នុងការតវ៉ានោះ បានប្រែក្លាយទៅជាមានសភាពហិង្សា និងធ្វើឲ្យសន្តិសុខជាច្រើននាក់រងរបួស។[39] នៅក្នុងខែសីហា ដដែលនោះ សមាជិកព្រឹទ្ធសភាបក្សប្រឆាំងមួយរូប ត្រូវបានចាប់ខ្លួនដោយមិនមានការដកអភ័យឯកសិទ្ធិជាផ្លូវការឡើយ។[40] ក្នុងខែតុលា ឆ្នាំ២០១៥ តំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិ២នាក់ ត្រូវបានគេវាយប្រហារដោយហិង្សា នៅក្នុងការតវ៉ាមួយដែលទំនងជាមានការរៀបចំទុកដែលការតវ៉ានោះមានអ្នកតវ៉ាគាំទ្ររដ្ឋាភិបាលប្រហែល២០០០នាក់ នៅក្រៅរបងទ្វាររដ្ឋសភា ហើយក្រោយមកបុរសបីនាក់មកពីកងអង្គរក្សរបស់នាយករដ្ឋមន្ត្រី ត្រូវបានផ្តន្ទាទោសពីបទវាយប្រហារនោះ។[41] ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ បន្ទាប់មានការចោទប្រកាន់ជាលក្ខណៈប្រវត្តិសាស្ត្រពីបទ "កុប្បកម្ម" និងការចេញដីកាចាប់ខ្លួនលោក សម រង្ស៊ី មក លោក សម រង្ស៊ី បានបន្តរស់នៅបរទេសដោយការនិរទេសខ្លួន។[42] (មួយឆ្នាំក្រោយមក គាត់ត្រូវបានគេហាមមិនឲ្យចូលក្នុងប្រទេសរបស់ខ្លួនវិញ តាមរយៈការណែនាំរដ្ឋបាល ដែលក្រោយមកត្រូវបានរដ្ឋាភិបាលដកចេញវិញ ក្រោយការបោះឆ្នោតឃុំសង្កាត់)។[43] ការវិវត្តន៍ដែលមានការពាក់ព័ន្ធគ្នាមួយទៀត គឺការដាក់ចេញច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលទទួលរងការរិះគន់ជាញឹកញយ ដោយសារតែការរឹតត្បឹតទៅលើការងាររបស់ស្ថាប័នឯករាជ្យ ធ្វើការលើបញ្ហាសិទ្ធិមនុស្ស។[44]

---

[38] មាត្រា 151, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[39] https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=23071

[40] KHM 7/2015, https://spdb.ohchr.org/hrdb/32nd/public_-_UA_Cambodia_21.12.15_(7.2015).pdf

[41] https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?LangID=E&NewsID=16795; KHM 6/2015, https://spdb.ohchr.org/hrdb/32nd/public_-_AL_Cambodia_03.12.15_(6.2015).pdf

[42] KHM 7/2015, https://spdb.ohchr.org/hrdb/32nd/public_-_UA_Cambodia_21.12.15_(7.2015).pdf

[43] KHM 7/2016, https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=22853

[44] A/HRC/33/62, Para 29; KHM 2/2015, https://spdb.ohchr.org/hrdb/30th/Public_-_OL_Cambodia_08.05.15_(2.2015).pdf; https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=16240&LangID=E

14. សមាជិកគណបក្សសង្គ្រោះជាតិមួយចំនួនទៀត ត្រូវបានចោទប្រកាន់ក្នុងឆ្នាំ២០១៦ ដោយរួមមានទាំងតំណាងរាស្ត្រដែលភាគច្រើនបំផុត មិនមានការដកអភ័យឯកសិទ្ធិជាផ្លូវការឡើយ។ បទចោទបរិហារកេរ្តិ៍ ឬការប៉ុនប៉ងសូកប៉ាន់សាក្សីត្រូវបានដាក់ប្តឹងទៅលើលោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិ និងបុគ្គលិកអង្គការសង្គមស៊ីវិល។[45] គាត់បានបដិសេធមិនបង្ហាញខ្លួន សម្រាប់ការសួរចម្លើយនិងត្រូវបានរកឃើញថាមានទោសក្នុងខែកញ្ញា ឆ្នាំ២០១៦។[46] ទោះបីក្រោយមក ត្រូវបានទទួលការលើកលែងទោសពីព្រះមហាក្សត្រ និងចេញពីការដាក់ឃុំខ្លួនឯងក្នុងផ្ទះក៏ដោយ ក៏តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមួយរូបត្រូវបានកាត់ឲ្យជាប់ពន្ធនាគារចំនួន២ឆ្នាំកន្លះ (បទញុះញង់) និងសមាជិកព្រឹទ្ធសភាដែលគាំទ្រគណបក្សសង្គ្រោះជាតិ ក៏ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន៧ឆ្នាំ (បទក្លែងបន្លំឯកសារនិងការញុះញង់) និង ១៨ខែ (បទបរិហាកេរ្តិ៍និងញុះញង់) ដោយសារការបញ្ចេញមតិយោបល់នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។[47] លោក អ៊ុំ សំអាន ដែលជាតំណាងរាស្ត្រ នៅស្ថិតក្រោមការឃុំខ្លួននៅឡើយ នៅពេលសរសេររបាយការណ៍នេះ។

15. ក្នុងខែមិនា ឆ្នាំ២០១៧ រដ្ឋសភា បានអនុម័តការធ្វើវិសោធនកម្មទៅលើច្បាប់ស្តីពីគណបក្សនយោបាយ ដែលបុគ្គលណាមួយដែលត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារដោយមិនមានការព្យួរទោស ត្រូវហាមឃាត់មិនឲ្យទទួលតំណែងនយោបាយ ខណៈដែលគេអាចរំលាយគណបក្សណាមួយបាន ពីបទអបគមន៍ ឬវិទ្ធង្សនា។[48] ប្រការនេះ បានបង្ខំឲ្យលោក សម រង្ស៊ី លាលែងតំណែងពីប្រធានគណបក្សសង្គ្រោះជាតិ និងបុគ្គលជាច្រើនបានលាលែងចេញពីគណៈកម្មាធិការនាយក។ OHCHR បានលើកឡើងនូវក្តីបារម្ភអំពីបទប្បញ្ញត្តិនៃច្បាប់នេះ ដែលមិនស៊ីសង្វាក់នឹងកាតព្វកិច្ចច្បាប់អន្តរជាតិរបស់ប្រទេសកម្ពុជា។[49] ច្បាប់នេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតក្នុងខែកក្កដា ឆ្នាំ២០១៧ ដែលរារាំងរាល់គណបក្សនយោបាយមិនឲ្យមានការពាក់ព័ន្ធជាមួយឬប្រើប្រាស់សារសម្លេង រូបភាព ឯកសារសំណេរ ឬសកម្មភាពនានា របស់បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយសារបទល្មើសឧក្រិដ្ឋ។ ការដាក់ទណ្ឌកម្ម រួមមានដូចជា ការហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយរហូតដល់៥ឆ្នាំ ការហាមឃាត់មិនឲ្យចូលរួមក្នុងការបោះឆ្នោត ឬអាចសូម្បីតែរំលាយគណបក្ស ទៀតផង។[50]

## IV. ការបោះឆ្នោតមូលដ្ឋានឆ្នាំ២០១៧ និងរឿងរ៉ាវក្រោយបោះឆ្នោត

16. ក្នុងខែមិថុនា ២០១៧ គណបក្សប្រជាជនកម្ពុជា បានទទួលតំណែងភាគច្រើន ប៉ុន្តែជាថ្មីម្តងទៀត គណបក្សសង្គ្រោះជាតិ បានទទួលសន្លឹកឆ្នោតប្រហែល៤៤% ដែលជាលទ្

[45] A/HRC/33/62, para 7; KHM 3/2016, https://spcommreports.OHCHR.org/TMResultsBase/DownLoadPublicCommunicationFile?gId=19826

[46] A/HRC/36/32, para 9

[47] A/HRC/36/61, para 7

[48] https://cambodia.OHCHR.org/sites/default/files/Analysis%20on%20the%20Amended%20Law%20on%20Political%20Parties%2028%2003%202017%20FINAL%20no%20TC.pdf

[49] https://www.OHCHR.org/EN/NewsEvents/Pages/DisplayNews.aspx?LangID=E&NewsID=22174

[50] A/HRC/39/73, para 68

ផលដែលមានភាពស៊ីសង្វាក់ជាមួយលទ្ធផលក្នុងការបោះឆ្នោតជាតិឆ្នាំ២០១៣។

17. ការបោះឆ្នោត ត្រូវបានកោតសរសើរជាទូទៅថាបានប្រព្រឹត្តិទៅ ដោយសន្តិវិធី មានសណ្តាប់ធ្នាប់ល្អ និងមានតម្លាភាពជារួម ដោយមានរបាយការណ៍តិចតួចអំពីភាពមិនប្រក្រតី និងមានដំណើរការចុះឈ្មោះអ្នកបោះឆ្នោតដែលមានភាពល្អប្រសើរច្រើន។[51] ក៏ប៉ុន្តែ មានបរិយាកាសនិងរបាយការណ៍ស្តីពីភាពតានតឹងមុនបោះឆ្នោតមួយចំនួន ទាក់ទងនឹងការបំភិតបំភ័យពីរដ្ឋាភិបាល។ ជាពិសេស អ្នករាយការណ៍ពិសេស បានទទួលរបាយការណ៍ថា អ្នកនយោបាយគណបក្សប្រឆាំង ត្រូវបានគេគំរាមកំហែង និងរារាំងមិនឲ្យធ្វើយុទ្ធនាកា និងរបាយការណ៍អំពីអ្នកតាមដានការបោះឆ្នោតពីអង្គការសង្គមស៊ីវិលមួយចំនួន ដែលបានទទួលរងការបំភិតបំភ័យនិងការយាយីខាន។[52] នៅក្នុងករណីមួយចំនួន មន្ត្រីមូលដ្ឋានរបស់គណបក្សប្រជាជនកម្ពុជា បានជំរុញយ៉ាងច្បាស់ក្រឡែតឲ្យអ្នកគាំទ្រអតីតអ្នកគាំទ្រគណបក្សប្រឆាំង ឲ្យចុះឈ្មោះសមាជិកគ្រួសាររបស់ខ្លួន នៅក្នុងសៀវភៅសមាជិករបស់គណបក្សប្រជាជនកម្ពុជា។ ប៉ុន្តែថ្ងៃមុនការបោះឆ្នោត មន្ត្រីជាន់ខ្ពស់មួយចំនួនបានលើកឡើងសង្កត់ធ្ងន់ជាថ្មីម្តងទៀត អំពីកក្តីភាពរបស់យោធា ចំពោះគណបក្សកាន់អំណាច និងបានព្រមានថា សង្គ្រាមស៊ីវិលនឹងត្រូវផ្ទុះឡើង ប្រសិនបើគណបក្សប្រឆាំងឈ្នះការបោះឆ្នោត ឬមានការតវ៉ាលទ្ធផលបោះឆ្នោតឃុំសង្កាត់។[53] នៅក្នុងសុន្ទរកថាមួយ នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ លោកនាយករដ្ឋមន្ត្រីបានថ្លែងថា គាត់សុខចិត្តជម្រុះចោលមនុស្ស១០០ ទៅ២០០នាក់ ដើម្បីសង្គ្រោះមនុស្សរាប់លានអ្នក។[54]

## A. ការរំលាយគណបក្សសង្គ្រោះជាតិ

18. នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ លោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួន ដោយសារមូលហេតុចង់ផ្តួលរំលំរដ្ឋាភិបាល តាមរយៈអ្វីដែលគេហៅថា "បដិវត្តពណ៌" ដែលមានការគាំទ្រដោយបរទេស។[55] ការចោទប្រកាន់ ផ្អែកទៅលើមតិយោបល់ដែលគាត់បានថ្លែងនៅប្រទេសអូស្ត្រាលីអំពីយុទ្ធសាស្ត្រនយោបាយនៅថ្នាក់មូលដ្ឋាន ដើម្បីទប់ទល់ប្រជែងជាមួយរដ្ឋាភិបាលបច្ចុប្បន្ន។ ទោះបីជាការថ្លែងនោះ បានកន្លងផុតទៅយូរហើយក៏ដោយក្តី ក៏ប៉ុន្តែដោយសារតែការថ្លែងយោបល់នោះ នៅតែអាចរកបាននៅតាមប្រព័ន្ធអ៊ីនធឺណែតនោះ គេបានចាត់ទុកវាជាបទល្មើសជាក់ស្តែង ហើយដោយយោងតាមវិធានផ្ទៃក្នុង រដ្ឋសភាពបានអនុញ្ញាតិឲ្យដំណើរការនីតិវិធី ដោយមិនចាំបាច់ដកអភ័យឯកសិទ្ធិសភាឡើយ។[56] បន្ទាប់មក លោក កឹម សុខា ត្រូវបានចោទប្រកាន់ពីបទចូលសន្និដ្ឋិភាពជាមួយបរទេសដើម្បីបង្កើតឲ្យមានអំពើប្រទូស្តរ៉ាយ ឬឲ្យមានអំពើឈ្លានពានប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា។។ គាត់បន្តនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន រហូតដល់ខែសីហា ឆ្នាំ២០១៨ ដោយមានការរឹតត្បឹតក្នុងការអនុញ្ញាតិឲ្យមានអ្នកសួរសុខទុក្ខ

[51] A/HRC/36/61, paras 59-60; A/HRC/36/32, para 17
[52] A/HRC/36/61, para 63
[53] A/HRC/36/32, para 16
[54] https://www.cambodiadaily.com/editors-choice/hun-sen-goes-tirade-opponents-130441/
[55] KHM 5/2017, https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=23334; see also CCPR/C/51/D/414/1990 at para 6.8
[56] Article 80, Constitution of Cambodia

ទោះបីជាក្រុមការងាររបស់អង្គការសហប្រជាជាតិស្តីពីការឃុំខ្លួនតាមទំនើងចិត្ត រកឃើញថា ការឃុំខ្លួនគាត់ ជាការធ្វើតាមទំនើងចិត្ត កាលពីខែមេសា ឆ្នាំ២០១៨ ក៏ដោយ។[57]

19. ការចាប់ខ្លួនលោក កឹម សុខា បានកើតឡើងបន្ទាប់ពីមានការបង្ក្រាបជាទូទៅទៅលើសមាជិកនិងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ។ បន្ទាប់មកទៀត មានការទទួលបានព័ត៌មានម្តងហើយម្តងទៀត អំពីការរំខានដល់កិច្ចប្រជុំរបស់គណបក្សសង្គ្រោះជាតិ និងដល់ការបំផ្លាញស្លាកទាមទារឲ្យមានការដោះលែងលោក កឹម សុខា នៅក្នុងខេត្តមួយចំនួន។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានរាយការណ៍ថា អតីតសមាជិកគណបក្សសង្គ្រោះជាតិមួយចំនួន បានទាក់ទងទៅបុគ្គលិករបស់ខ្លួន ទាក់ទឹងនឹងការបំភិតបំភ័យនិងការគំរាមចាប់ខ្លួនពីប៉ូលីស។[58]

20. ក្នុងខែតុលា ឆ្នាំ២០១៧ បន្ទាប់ពីមានបណ្តឹងដោយគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សយុវជនកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដាក់សំណើមួយទៅតុលាការកំពូល ក្រោមច្បាប់ស្តីពីគណបក្សនយោបាយដែលទើបនឹងធ្វើវិសោធនកម្មរួច សុំរំលាយគណបក្សប្រឆាំង។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ តុលាការកំពូល ដឹកនាំដោយប្រធានក្រុមចៅក្រមនិងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សប្រជាជនកម្ពុជា បានរំលាយគណបក្សសង្គ្រោះជាតិនិងហាមឃាត់សមាជិកជាន់ខ្ពស់ចំនួន១១៨នាក់ មិនឲ្យចូលរួមក្នុងសកម្មភាពនយោបាយរយៈពេល៥ឆ្នាំ។[59] វាជាការព្រួយបារម្ភមួយដោយភស្តុតាងដែលដាក់ដោយក្រសួងមហាផ្ទៃ និងភស្តុតាងដែលតុលាការកំពូលផ្អែកទៅលើ សម្រាប់ការរំលាយគណបក្សសង្គ្រោះជាតិ គឺផ្នែកខ្លះ ជាការចោទប្រកាន់តែមួយដែលបច្ចុប្បន្នស្ថិតនៅក្រោមការស៊ើបអង្កេតរបស់ចៅក្រមស៊ើបសួរនៅឡើយ ទាក់ទងនឹងបទចោទប្រឆាំងលោក កឹម សុខា។ គណបក្សសង្គ្រោះជាតិ មិនបានដាក់ការការពារទេ ហើយតុលាការកំពូលក៏មិនបានធ្វើពិសោធន៍ទៅលើភស្តុតាងរបស់រដ្ឋាភិបាលដែរ។ នេះជាការលើកឡើងនូវក្តីបារម្ភធ្ងន់ធ្ងរ អំពីមូលដ្ឋានភស្តុតាងសម្រាប់ការធ្វើសេចក្តីសម្រេចក្នុងការរំលាយ។

21. ក្នុងការចាត់វិធានការមុន ដើម្បីគាំទ្រដល់សេចក្តីសម្រេចរបស់តុលាការកំពូល រដ្ឋសភាជាតិ បានអនុម័តទៅលើវិសោធនកម្មទៅលើច្បាប់ទាក់ទងនឹងការបោះឆ្នោតមួយចំនួននៅក្នុងខែតុលា ឆ្នាំ២០១៧។ នេះជាការផ្តល់នូវដំណើរការមួយសម្រាប់ការបែងចែកអាសនៈរបស់គណបក្សដែលត្រូវរំលាយចោល។ តាមសេចក្តីណែនាំទាំងនេះ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ គ.ជ.ប បានបែងចែកអាសនៈទាំង៥៥ របស់គណបក្សសង្គ្រោះជាតិឡើងវិញ ឲ្យទៅគណបក្សនយោបាយ ៣ផ្សេងទៀត (ហ៊្វុនស៊ិនប៉ិច ៤១, គណបក្សសញ្ជាតិកម្ពុជា ២, និងគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ១)។ គណបក្សពីរផ្សេងទៀត បានបដិសេធមិនទទួលអាសនៈ (គណបក្សសម្ព័ន្ធដើម្បីលទ្ធិប្រជាធិបតេយ្យ និងគណបក្សខ្មែរឈប់ក្រ) ហេតុដូចនេះហើយ អាសនៈនៅសល់ចំនួន១១ របស់អតីតគណបក្សសង្គ្រោះជាតិ ត្រូវបានបែងចែងទៅឲ្យគណបក្សប្រជាជនកម្ពុជា។

22. តំណែងថ្នាក់ឃុំសង្កាត់ ដែលគណបក្សសង្គ្រោះជាតិទទួលបានក្នុងការបោះឆ្នោតខែ

[57] A/HRC/WGAD/2018/9

[58] A/HRC/37/64, para 6

[59] See also CCPR/C/12/D/34/1978, paras. 8.4 and 9

មិថុនា ឆ្នាំ២០១៧ ក៏ត្រូវបាន គ.ជ.ប បែងចែកបន្តក្នុងខែធ្នូ ឆ្នាំ២០១៧ដែរ។ គណបក្សប្រជាជនទទួលបានតំណែងចំនួន ៤៥៤៨ ពីតួនាទីចំនួន៥០០៧ និងតំណែងជាមេឃុំ/ចៅសង្កាត់ចំនួន៤៨៩ របស់គណបក្សសង្គ្រោះជាតិ។ តំណែងតួនាទីក្រុមប្រក្សាឃុំសង្កាត់ដែលនៅសល់ ២៤០ ផ្តល់ទៅឲ្យគណបក្សសហ្វ៊ុនស៊ិនប៉ិច, ២០៣ ផ្តល់ទៅឲ្យគណបក្សខ្មែររួបរួមជាតិ, ១០ ផ្តល់ទៅឲ្យគណបក្សសញ្ជាតិកម្ពុជា ៣ ផ្តល់ឲ្យគណបក្សយុវជនកម្ពុជា និង ចំនួន៣ទៀតផ្តល់ឲ្យ គណបក្សជនជាតិដើមប្រជាធិបតេយ្យ កម្ពុជា។

23. ការបែងចែកអាសនៈឡើងវិញនេះ បង្កើតឲ្យមានបញ្ហា ធ្ងន់ធ្ងរមួយចំនួន ទាក់ទឹងនឹងភាពជាតំណាងផ្នែកនយោបាយរបស់ប្រជាជនកម្ពុជាមួយភាគធំ និងជាការធ្វើឲ្យកាន់តែប៉ះពាល់បន្ថែមចំពោះដំណើរការរំលាយគណបក្សសង្គ្រោះជាតិ ដែលពោរពេញដោយការសង្ស័យជាច្រើនទៅហើយនោះ។ ការបែងចែកអាសនៈឡើងវិញនេះ ជាការដកហូតសិទ្ធិចូលរួមក្នុងវិស័យនយោបាយ របស់ប្រជាជនកម្ពុជារាប់លាន យ៉ាងជាក់ស្តែងបំផុត។ សម្រាប់អ្នកដែលបានបោះឆ្នោតគាំទ្រគណបក្សសង្គ្រោះជាតិក្នុងការបោះឆ្នោតជាតិឆ្នាំ ២០១៣ និងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧នោះ បេក្ខជនដែលពួកគេបានបោះឆ្នោតជូន ត្រូវបានផ្លាស់ប្តូរដោយមនុស្សដែលមិនទទួលបានការបោះឆ្នោតគាំទ្រ ហើយដែលតំណាងឲ្យគណបក្សនយោបាយផ្សេងទៀត ដែលនឹងត្រូវរក្សាអាណត្តិនេះរហូតដល់ឆ្នាំ ២០២២ សម្រាប់មន្ត្រីមូលដ្ឋាន។ សិទ្ធិចូលរួមក្នុងការធ្វើកិច្ចការនយោបាយ បង្ហាញអំពីសិទ្ធិត្រូវបានតំណាង តាមរយៈតំណាងដែលប្រជាជនបានជ្រើសរើស។ ការរំពឹងទុកដែលបានសម្តែងលើកឡើងក្នុងឆ្នាំ២០១៣ និង២០១៧ ប្រកបដោយសន្តិវិធី ដែលអាចនាំទៅរកការផ្លាស់ប្តូររដ្ឋាភិបាលតាមបែបប្រជាធិបតេយ្យ បានដើរត្រឡប់ក្រោយវិញយ៉ាងរហ័ស។

24. ការបោះឆ្នោតព្រឹទ្ធសភា បានរៀបចំឡើងនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។ ក្នុងចំណោមសមាជិកព្រឹទ្ធសភាចំនួន៦២នាក់នោះ ៥៨នាក់ ត្រូវបានបោះឆ្នោតដោយប្រយោលដោយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ និងដោយសមាជិករដ្ឋសភា (អាសនៈដែលនៅសល់ ២រូបត្រូវបានតែងតាំងដោយព្រះមហាក្សត្រ និងពីររូបដោយសមាជិកសភា។ ការបោះឆ្នោតនេះ មិនមានការប្រជែងសោះឡើយ ដោយសារអាសនៈឃុំនិងសភារបស់គណបក្សសង្គ្រោះជាតិ (ប្រហែល៤៣% នៃចំនួនអ្នកបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា) ត្រូវបានបែងចែករួចទៅហើយនោះ។ គណបក្សប្រជាជនកម្ពុជា មានសមាជិកជាអ្នកបោះឆ្នោតប្រហែល៩៥% ហើយទទួលបានអាសនៈទាំង៥៨ នៅក្នុងព្រឹទ្ធសភា។ ទោះបីជាការបោះឆ្នោតព្រឹទ្ធសភា ជាការបោះឆ្នោតដោយប្រយោលក៏ដោយ ក៏លទ្ធផល បានឆ្លុះបញ្ចាំងអំពីការដកហូតនូវសិទ្ធិនយោបាយរបស់ប្រជាជនខ្មែររាប់លាននាក់ ដោយសារតែការបែងចែកអាសនៈឃុំសង្កាត់ឡើងវិញ ហើយដែលអាសនៈនៅព្រឹទ្ធសភាទាំងនោះ អាចមានរយៈពេលដល់ទៅ៦ឆ្នាំខាងមុខ។

## B. ផលប៉ះពាល់ទៅលើសិទ្ធិបុគ្គលនិងក្រុមជាក់លាក់

### (a) សមាជិកនិងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ

25. បន្ទាប់ពីការសម្រេចរបស់តុលាការកំពូល មានការទទួលបានព័ត៌មានជឿជាក់អំពីការ

កើនឡើងនៃនៃការដាក់គំនាប និងបំភិតបំភ័យទៅលើអតីតសមាជិកគណបក្សសង្គ្រោះជាតិជាច្រើនអ្នកដែលភាគច្រើនគឺដើម្បីឲ្យពួកគេ "ចុះចូល" ជាមួយគណបក្សប្រជាជនកម្ពុជា។ ឧទាហរណ៍ នៅថ្ងៃទី១៨ ខែវិច្ឆិកា អតីតមន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិក្នុងខេត្តកំពង់ឆ្នាំង ត្រូវបានមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាល គំរាមកំហែងអំពីការជាប់ពន្ធនាគារ ប្រសិនបើពួកគេបដិសេធមិនចូលរួមជាមួយគណបក្សប្រជាជនកម្ពុជាទេនោះ។ អតីតមន្ត្រីគណបក្សសង្គ្រោះជាតិក្នុងខេត្តកំពង់ឆ្នាំងជាង៥០នាក់ បានដូរចូលទៅគណបក្សប្រជាជនកម្ពុជា នៅត្រឹមចុងខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីបានបន្តកាន់កាប់តួនាទីរបស់ខ្លួន។ ក្នុងករណីមួយផ្សេងទៀត អតីតថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ ក្នុងភាគពាយព្យនៃប្រទេសកម្ពុជា បានរាយការណ៍អំពីការបំភិតបំភ័យ ដោយមេបញ្ជាយោធាមូលដ្ឋាន ដោយមានអមដោយទាហានប្រដាប់អាវុធចំនួន៣០នាក់ បន្ទាប់ពីគាត់បដិសេធមិនព្រមចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។ អ្នកផ្សេងទៀត ក៏បានរាយការណ៍អំពីឧបទ្ទវហេតុស្រដៀងគ្នានេះ នៅក្នុងខេត្តផ្សេងទៀតដែរ។

26. អ្នកមួយចំនួនបានបដិសេធមិនព្រមចុះចូល ដោយរួមមានទាំង លោក ឈុន សិទ្ធី អាយុ៣៨ឆ្នាំ ដែលជាអតីតក្រុមប្រឹក្សាឃុំមកពីគណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួនដោយគ្មានដីកានៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៧។ យោងតាមព័ត៌មានដែលបានទទួល ប៉ូលីសបានសាកសួរគាត់ ទាក់ទងនឹងវីដេអូចំនួន៣នាទីនៅលើ Facebook ដែលគាត់បានឆ្លើយតបកាលពីថ្ងៃទី២២ ខែតុលា ទៅនឹងការអំពាវនាវរបស់លោកនាយករដ្ឋមន្ត្រីឲ្យសមាជិកគណបក្សសង្គ្រោះជាតិ ចុះចូល ដើម្បីរក្សាការងាររបស់ខ្លួន។ នៅក្នុងវីដេអូនោះ លោក សិទ្ធី មានការសង្ស័យអំពីភាពឆ្លាតវៃរបស់លោកនាយករដ្ឋមន្ត្រី ក្នុងការផ្ដល់លុយនិងបាននិយាយថា គាត់នឹងមិនទទួលលុយចំនួន ៥៧០.០០០ រៀល រឺហូតដល់ ៥៧០.០០០ ដុល្លារអាមេរិចនោះទេ។ គាត់ត្រូវបានចោទពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រមាថមន្ត្រីសាធារណៈ ហើយចុងក្រោយ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨លានរៀល (២០០០ ដុល្លារ) កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៨។

27. សមាជិកអតីតគណបក្សសង្គ្រោះជាតិជាច្រើននាក់ បើតាមសេចក្ដីរាយការណ៍ដែលទទួលបានរួមមានពាក់កណ្ដាលនៃសមាជិកជាន់ខ្ពស់ទាំង១១៨នាក់ ដែលត្រូវបានគេហាមមិនឲ្យធ្វើនយោបាយផងដែរបានភៀសខ្លួនចេញទៅក្រៅប្រទេស មុននិងក្រោយមានការសម្រេចចិត្តរបស់តុលាការកំពូល ដោយមានការភ័យខ្លាចការចាប់ខ្លួន។ លោកស្រី សួរ សែម អាយុ៣៤ឆ្នាំ ដែលជាអតីតក្រុមប្រឹក្សាឃុំរបស់គណបក្សសង្គ្រោះជាតិមកពីប៉ៃលិន បានភៀសខ្លួនទៅបរទេស នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ បន្ទាប់ពីទទួលបានដីកាកោះហៅពីតុលាការ ពីបទរួមផ្សំគំនិតក្បត់ជាតិ និងចារកម្ម ដែលបានប្រព្រឹត្តិនៅចន្លោះរវាងខែមិថុនា និងខែតុលា ឆ្នាំ២០១៧។ យោងតាមព័ត៌មានដែលទទួលបាន លោកស្រីទទួលរងគំនាបសង្កត់ ពេញមួយខែវិច្ឆិកា ពីមន្ត្រីនៅកម្រិតផ្សេងៗគ្នា ឲ្យលោកស្រីចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ហើយលោកស្រីថែមទាំងបានបដិសេធន៍ការស្នើសុំលាយលក្ខណ៍អក្សរជាផ្លូវការ ដែលបានទទួលកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧។ ដីកាចាប់ខ្លួន ត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ដោយដីកានេះ ត្រូវបានចែករំលែកមកដល់អ្នករាយការណ៍ពិសេស។

28. ស្រដៀងគ្នានេះដែរ លោក អូន ស្រៀង ដែលសមាជិកគណៈកម្មាធិការប្រតិបត្តិខេត្ត មកពីអតីតគណបក្សសង្គ្រោះជាតិ ក្នុងខេត្តឧត្តរមានជ័យ បានភៀសខ្លួនទៅកាន់ប្រទេសថៃ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៧ បន្ទាប់ពីតុលាការខេត្ត បានចេញដីកាកោះហៅគាត់ នៅថ្ងៃទី៨ ខែវិច្ឆិកា។ ការកោះហៅនេះ មានការជាប់ទាក់ទងទៅនឹងការអះអាងរបស់គាត់ កាលពីខែសីហា ឆ្នាំ២០១៦ ដែលថាអាជ្ញាធរមូលដ្ឋាន ជាអ្នកនៅពីក្រោយការបាញ់ស្លាកសញ្ញាមួយរបស់គណបក្សសង្គ្រោះជាតិ ហើយដែលពីរឆ្នាំក្រោយមក គាត់ត្រូវបានស៊ើបអង្កេតពីបទការបរិហារជាសាធារណៈ និងការញុះញង់ឲ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ។ ការប៉ុនប៉ងអូសទាញគាត់ឲ្យចុះចូល បន្តកើតមាន ទោះបីជាក្រោយពេលដែលគាត់បានភៀសខ្លួនហើយក៏ដោយ។ នៅចុងខែវិច្ឆិកា គាត់បានរាយការណ៍ថា មានការទាក់ទងនៅតាម Facebook ពីអតីតមេឃុំគណបក្សសង្គ្រោះជាតិ ដែលបានផ្លាស់ចូលទៅគណបក្សប្រជាជនកម្ពុជា ដែលបានប្រាប់គាត់ថា ប្រសិនបើគាត់ត្រឡប់មកវិញនិងចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា បណ្តឹងនោះអាចដោះស្រាយបាន។

29. ពីខែកញ្ញាដល់ខែវិច្ឆិកា ឆ្នាំ២០១៧ ថ្នាក់ដឹកនាំនិងសមាជិកអតីតគណបក្សសង្គ្រោះជាតិចំនួនប្រមាណ២២០នាក់ ត្រូវបានរាយការណ៍ថា បានភៀសខ្លួនទៅប្រទេសថៃ ដោយក្នុងនោះ ភាគច្រើនកំពុងស្វែងរកឋានៈជាជនភៀសខ្លួន។ សមាជិក៥០-៦០នាក់ផ្សេងទៀតត្រូវបានរាយការណ៍ថាកំពុងរស់នៅជិតព្រំដែនកម្ពុជា-ថៃ។ អ្នកទាំងនេះត្រូវបានអាជ្ញាធរថៃព្រមាន មិន ឲ្យធ្វើសកម្មភាពនយោបាយឡើយ។ ពួកគាត់ភាគច្រើន បានអះអាងថា មានការតាមដាននិងបំភិតបំភ័យ ដោយភ្នាក់ងារកម្ពុជា និងអាជ្ញាធរថៃ ព្រមទាំងមានការភ័យខ្លាចថាត្រូវគេចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញទៀតផង។

30. ការភ័យខ្លាចថាត្រូវគេបង្ខំឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ មួយផ្នែកដោយសារតែករណីលោកស្រី សំ សុខា មកពីខេត្តកំពង់ស្ពឺ។ ក្នុងខែមេសា ឆ្នាំ២០១៧ លោកស្រីបានផ្សាយវីដេអូមួយនៅតាម Facebook បង្ហាញពីខ្លួនឯង គប់ស្បែកជើងទៅលើស្លាកសញ្ញាគណបក្សប្រជាជនកម្ពុជា ដែលមានរូបរបស់លោកនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភាជាតិ ដោយគាត់បាននិយាយថា ពួកគេកំពុងបំផ្លាញជាតិ។ លោកស្រីត្រូវបានចោទប្រកាន់ពីបទការប្រមាថមន្ត្រីសាធារណៈ និងការញុះញង់ឲ្យមានការរើសអើង និងត្រូវបានផ្តន្ទាទោសកំបាំងមុខ ដាក់ពន្ធនាគារចំនួនពីរឆ្នាំ ក្នុងខែមករា ឆ្នាំ២០១៨ និងពិន័យជាប្រាក់ចំនួន៥លានរៀល (១២៥០ ដុល្លារ)។ ថ្វីត្បិតតែទទួលបានឋានៈជាជនភៀសខ្លួនតាមរយៈឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនក៏ដោយ ក៏លោកស្ត្រីត្រូវបានធ្វើបត្យាប័នដោយអាជ្ញាធរថៃ នៅថ្ងៃទី៨ ខែកុម្ភៈ ក្រោយមានស្នើសុំពីរដ្ឋាភិបាលកម្ពុជា។ បន្ថែមពីលើការទទួលទោស ដោយសារតែការអនុវត្តសិទ្ធិសេរីភាពក្នុងការសម្តែងមតិនោះ ឥឡូវនេះ លោកស្រីកំពុងតែទទួលការជំនុំជម្រះទៅលើការចោទប្រកាន់ពីបទញុះញង់ឲ្យមានការរើសអើង ដែលជាប់ទាក់ទងនឹងសេចក្តីថ្លែងការណ៍ដែលគេចោទថាបានធ្វើនៅក្នុងប្រទេសថៃ។

31. អតីតសមាជិកគណបក្សសង្គ្រោះជាតិដែលបន្តរស់នៅក្នុងប្រទេសកម្ពុជា បានរាយការណ៍អំពីការរស់នៅដោយភាពភ័យខ្លាច មិនអាចបញ្ចេញមតិយោបល់ផ្នែកនយោបាយដោយសេរីទេ។ ឧទាហរណ៍ ក្នុងខែឧសភា ឆ្នាំ២០១៨ អតីតអនុប្រធានគណបក្សសង្គ្រោះជាតិ លោក ប៉ុល ហំ បានប្រាប់អ្នកសារព័ត៌មានថា គាត់ចង់បញ្ចេញទស្សនៈស្តីពីបញ្ហា

នយោបាយបច្ចុប្បន្ន ប៉ុន្តែត្រូវបង្ខំចិត្តបិទមាត់វិញ។[60] សមាជិកនិងអ្នកគាំទ្រអតីតគណបក្សសង្គ្រោះជាតិ ក៏បានរាយការណ៍អំពីការបន្តការឃើយាំខាននិងការបំភិតបំភ័យដែរ។ ឧទាហរណ៍ កញ្ញា ស៊ិន ចាន់ពៅរ៉ូហ្សិត អតីតចៅសង្កាត់គណបក្សសង្គ្រោះជាតិនៅសង្កាត់អូចារ ខេត្តបាត់ដំបង ដែលបច្ចុប្បន្នបើកភោជនីយដ្ឋានមួយ បានទទួលការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណែត ក្នុងខែមករា ឆ្នាំ២០១៨ ពីតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមួយរូប ដែលបានអះអាងថា ភោជនីយដ្ឋានរបស់នាងគឺជាទីកន្លែងសម្រាប់សកម្មភាពគណបក្សសង្គ្រោះជាតិដែលត្រូវហាមឃាត់នោះ។ នាងបានឆ្លើយតបដោយបានដាក់ស្លាកមួយនៅខាងក្រៅហាងរបស់នាងថា ហាងនេះរីករាយស្វាគមន៍ភ្ញៀវទាំងអស់ លើកលែងតែឧទ្ទាមជន។ ក៏ប៉ុន្តែ សាលាក្រុងបាត់ដំបង បានប្រាប់នាងឲ្យដកស្លាកនោះចេញ។ យោងតាមព័ត៌មានដែលបានទទួល នាងបន្តទទួលការគំរាមកំហែងម្តងម្កាល ដោយរួមទាំង មានមនុស្សមិនស្គាល់មុខបានមកផ្ទះនាងពេលយប់អាធ្រាត បានបំពានសម្តីមកលើនាងក្នុងសប្តាហ៍មុនការបោះឆ្នោតថ្នាក់ជាតិ។

32. មានការទទួលបានបណ្តឹងមួយចំនួនផ្សេងទៀត ដោយមានរួមទាំងបណ្តឹងរបស់អ្នកគាំទ្រអតីតគណបក្សសង្គ្រោះជាតិឬសាច់ញាតិរបស់ពួកគេ ដែលទទួលរងការគំរាមកំហែងនិងមានមន្ត្រីប៉ូលីសតាមដាន។ ឧទាហរណ៍ គ្រួសាររបស់ថ្នាក់ដឹកនាំម្នាក់ក្នុងខេត្តឧត្តរមានជ័យ បានបដិសេធសំណូមពររបស់មេភូមិក្នុងការចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា។ ក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ មានមនុស្សមិនស្គាល់មុខបានមកពេលកណ្តាលយប់ចំនួនបីដង ដោយបានបំផ្លាញសម្ភារៈក្នុងផ្ទះបាយនិងទ្រព្យសម្បត្តិផ្សេងៗទៀត នៅក្នុងបរិវេណដីនិងបានបន្ទោរបង់លាមក នៅទីនោះទៀតផង។ ដោយមិនមានការគាំទ្រច្រើនពីប៉ូលីស និងដោយការប្រឈមការគំរាមកំហែងកាន់តែកើនឡើងដោយសារការមកដល់របស់ជនមិនស្គាល់មុខនៅពាក់កណ្តាលយប់នោះ គ្រួសារនោះ បានរើចេញទៅរស់នៅខេត្តមួយផ្សេងទៀតនៅពាក់កណ្តាលខែកក្កដា ឆ្នាំ២០១៨។

33. លោក កឹម សុខា និង លោក សម រង្ស៊ី ត្រូវបានកោះហៅ ចោទប្រកាន់ ឬផ្តន្ទាទោសនៅក្នុងករណីជាច្រើន ដោយភាគច្រើនទៅលើបទល្មើសបរិហារកេរ្តិ៍ និងញុះញង់។[61] នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ លោក សម រង្ស៊ី បានប្រកាសអំពីចលនាសង្គ្រោះជាតិ។ ប៉ុន្មានថ្ងៃក្រោយមក ក្រសួងមហាផ្ទៃបានដំណើរការនីតិវិធីទៅលើលោក សម រង្ស៊ី និងថ្នាក់ដឹកនាំផ្សេងទៀត ពីបទ ញុះញង់និងបង្កចលាចលដើម្បីផ្តួលរំលំរដ្ឋាភិបាល។ យ៉ាងហោចណាស់សំណុំរឿងព្រហ្មទណ្ឌចំនួនបីត្រូវបានប្តឹងទៅលើលោកសម រង្ស៊ី នៅតុលាការក្រុងភ្នំពេញនៅចន្លោះរវាងខែធ្នូ ឆ្នាំ២០១៧ និងខែមិថុនា ឆ្នាំ២០១៨ ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍នៅលើ Facebook។ លោក សម រង្ស៊ី ក៏ត្រូវបានផ្តន្ទាទោសកំបាំងមុខ នៅក្នុងករណីមិនទាន់ចាត់ការពីមុនៗមកដែរ ដូចជា នៅថ្ងៃទី៦ មិនា ឆ្នាំ២០១៨ សាលាឧទ្ធរណ៍បានតម្កល់សាលក្រមសាលាដំបូងអំពីការបរិហារកេរ្តិ៍ជាសាធារណៈ ដោយសំណងជាប្រាក់ចំនួន ១០ លានរៀល (២៥០០ ដុល្លារ) និង៤ពាន់លានរៀល (១លានដុល្លារ) ទៅដល់លោកនាយករដ្ឋមន្ត្រី, នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ តុលាការបានសម្រេចរឹបអូសអចលនទ្រព្យរបស់គាត់នៅក្នុងប្រទេសកម្ពុជា ពាក់ព័ន្ធនឹងករណីបរិហារកេរ្តិ៍ដែលប្តឹងដោយលោកនាយករដ្ឋម

[60] https://www.phnompenhpost.com/national-politics/ex-cnrp-deputy-pol-ham-breaks-silence-talks- safety-concerns

[61] A/HRC/36/32, para 8

ន្ត្រីនិងប្រធានរដ្ឋសភាជាតិ។ នីតិវិធីព្រហ្មទណ្ឌផ្សេងទៀត នៅតែបន្តដំណើរការ។

34. ការរឹតត្បឹតដែលកើតក្រោយការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ មិនមែនកើតឡើងតែទៅលើគណបក្សនយោបាយប៉ុណ្ណោះទេ គឺវាបានលាតសន្ធឹងដល់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក្រុមសង្គមស៊ីវិល និងបុគ្គល ដែលគេចាត់ទុកថា ជាការគំរាមកំហែងដល់រដ្ឋាភិបាល។ ក្នុងការឆ្លើយតបចំពោះបញ្ហានេះ អ្នកនាំពាក្យរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស[62] បានលើកឡើងនូវក្តីបារម្ភក្នុងខែសីហា និងអគ្គលេខាធិការអង្គការសហប្រជាជាតិ[63] នៅក្នុងខែធ្នូ។

## (b) អង្គការសង្គមស៊ីវិលនិងអ្នកការពារសិទ្ធិមនុស្ស

35. សូម្បីនៅមុនការបោះឆ្នោតឃុំសង្កាត់ បរិយាកាសសម្រាប់សម្លេងជំទាស់ក្នុងប្រទេសកម្ពុជា មានការចុះដុនដាប ជាពិសេស តាមរយៈការឃុំខ្លួនតាមទំនើងចិត្តទៅលើបុគ្គលិកអង្គការអាដហុកទាំង៥ (បុគ្គលិក៤នាក់របស់អង្គការអាដហុក និងអតីតបុគ្គលិកម្នាក់ដែលបានផ្លាស់ទៅធ្វើការក្នុងតំណែងជាន់ខ្ពស់នៅ គ.ជ.ប) ក្នុងខែមេសា ឆ្នាំ២០១៦[64] និងមានអំពើឃាដកម្មទៅលើសកម្មជននិងអ្នកវិភាគ គឺលោក កែម ឡី ក្នុងខែកក្កដា ២០១៦[65]។ អ្នកវិភាគមួយរូបទៀត គឺលោក កឹម សុខ ត្រូវបានបានចាប់ខ្លួននិងចុងក្រោយកាត់ឲ្យជាប់ពន្ធនាគារចំនួន១៨ខែ ពីបទបរិហារកេរ្តិ៍ និងញុះញង់ ដោយយោងតាមការដែលគាត់បានលើកឡើងថា គណបក្សប្រជាជនកម្ពុជា ជាអ្នកទទួលខុសត្រូវទៅលើឃាដកម្មនេះ។ ក្រុមសង្គមស៊ីវិល ប្រឈមនឹងការឃាំឃីរំខាននិងការបំភិតបំភ័យជាប្រចាំ ដោយរួមមានទាំងអ្នកដែលចូលរួមនៅក្នុងយុទ្ធនាការ "ថ្ងៃច័ន្ទពណ៌ខ្មៅ" ដែលរំលេចឡើងអំពីការចាប់ខ្លួនបុគ្គលិកអង្គការអាដហុកទាំងប្រាំរូប។[66]

36. ក្នុងអំឡុងពេលបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ ក្រុមអង្គការនិងសមាគមចំនួនជាង ៤០ បានចូលរួមជាមួយគ្នាបង្កើតជា "បន្ទប់ស្ថានការណ៍" ដើម្បីឃ្លាំមើលបរិយាកាសមុនការបោះឆ្នោត និងថ្ងៃបោះឆ្នោត។ នៅប៉ុន្មានសប្តាហ៍ក្រោយពីការបោះឆ្នោត លោកនាយករដ្ឋមន្ត្រីបានអំពាវនាវឲ្យមានការស៊ើបអង្កេតមួយទៅលើ "បន្ទប់ស្ថានការណ៍"។ បន្ទាប់ពីនោះ អង្គការដែលធ្វើការលើការងារបោះឆ្នោតចំនួនពីរ គឺអង្គការខុមហ្រ្វែល និងអង្គការនិចហ្វិច បានទទួលការជូនដំណឹងថា បន្ទប់ស្ថានការណ៍ មិនមានការចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនោះទេ។ ក្នុងខែសីហា ឆ្នាំ២០១៧ អ្នករាយការណ៍ពិសេស បានពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ អំពីការយល់ឃើញរបស់លោកស្រីថា ដោយសារតែ បន្ទប់ស្ថានការណ៍មិនមែនជាអង្គការមិនមែនរដ្ឋាភិបាលមួយទេ គឺវាគ្រាន់តែ

[62] https://www.OHCHR.org/EN/NewsEvents/Pages/DisplayNews.aspx?LangID=E&NewsID=21996

[63] https://www.voacambodia.com/a/un-secretary-general-concerned-by-deteriorating-democratic-space- in-cambodia/4168302.html

[64] KHM 3/2016, https://spcommreports.OHCHR.org/TMResultsBase/DownLoadPublicCommunicationFile?gId=19826; KHM 6/2016, https://spcommreports.OHCHR.org/TMResultsBase/DownLoadPublicCommunicationFile?gId=22837; KHM 1/2017, https://spcommreports.OHCHR.org/TMResultsBase/DownLoadPublicCommunicationFile?gId=23142

[65] A/HRC/36/32, para 13; KHM 4/2016, https://spcommreports.OHCHR.org/TMResultsBase/DownLoadPublicCommunicationFile?gId=3255

[66] HRC/36/61, section IV

ជាក្រុមរបស់អង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីរួច ប្រមូលផ្តុំធនធាន និងធ្វើការរួមគ្នានោះ បន្ទប់ស្ថានការណ៍ មិនមានកាតព្វកិច្ចក្រោមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនោះទេ។[67]

37. នៅថ្ងៃទី២៣ ខែសីហា ការិយាល័យវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) នៅក្នុងប្រទេសកម្ពុជា ក្លាយទៅជាអង្គការមិនមែនរដ្ឋាភិបាលទីមួយដែលត្រូវបានបិទចោល ដោយការប្រើប្រាស់បទប្បញ្ញត្តិក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។ ទោះបីជាការបិទនេះ គឺដោយសារតែការមិនបានចុះបញ្ជីមែនក៏ដោយ ក៏មន្ត្រីរដ្ឋាភិបាលបានអះអាងម្តងហើយម្តងទៀតថា វិទ្យាស្ថានជាតិប្រជាធិបតេយ្យ បានចូលដៃជាមួយគណបក្សសង្គ្រោះជាតិ។ នៅថ្ងៃទី៣១ ខែតុលា សហព័ន្ធនិស្សិតបញ្ញវន្តកម្ពុជា ត្រូវបានព្យួរប្រតិបត្តិការបណ្តោះអាសន្នរយៈពេល៦០ថ្ងៃ ដោយសារតែការបំពានទៅលើលក្ខខណ្ឌតម្រូវនៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល អំពីអព្យាក្រឹត្យភាពផ្នែកនយោបាយ បន្ទាប់ពីនាយកសហព័ន្ធ បានអំពាវនាវនៅក្នុងកិច្ចសម្ភាសន៍មួយ ឲ្យប្រជាជនចូលរួមនៅក្នុងការតវ៉ាប្រឆាំងនឹងសំណើរំលាយគណបក្សសង្គ្រោះជាតិ។[68]

38. នៅចុងខែវិច្ឆិកា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ដែលជាអង្គការបង្កើតឡើងដំបូងដោយលោក កឹម សុខា ក្នុងឆ្នាំ២០០២ ក៏ត្រូវបានស៊ើបអង្កេតដែរ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រីថ្លែងនៅក្នុងសុន្ទរកថាមួយ ចោទប្រកាន់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ថាមានការជាប់ទាក់ទងជាមួយផែនការ "បដិវត្តពណ៌" ។[69] ទោះបីជាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានអនុញ្ញាតឲ្យបន្តប្រតិបត្តិការរបស់ខ្លួន ដែលជាជំហានត្រឹមត្រូវមួយក៏ដោយ[70] ក៏ការគំរាមកំហែងទៅលើអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដ៏ល្បីល្បាញមួយក្នុងចំណោមអង្គការផ្សេងទៀតនៅក្នុងប្រទេសកម្ពុជានោះ បានធ្វើឲ្យមានឥទ្ធិពលគួរឲ្យភ័យខ្លាច ដែលបានបណ្តាលឲ្យអង្គការមួយចំនួនក្នុងប្រទេសកម្ពុជាត្រូវអនុវត្តការកម្រិតសេរីភាពខ្លួនឯង (self-censorship) ដោយសារតែមានវិធានការរដ្ឋបាលនានា ត្រូវបានគេធ្វើប្រឆាំងនឹងអង្គការផ្សេងទៀត។ ក្នុងខែកញ្ញា រដ្ឋាភិបាលបានផ្អាកប្រតិបត្តិការរបស់អង្គការសមធម៌កម្ពុជាចំនួន៣០ថ្ងៃ និងបានលុបឈ្មោះអង្គការមាតាធម្មជាតិដែលប្រតិបត្តិការផ្នែកបរិស្ថាន។ បុគ្គលិករបស់អ្គការនេះចំនួនពីរនាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងការថតវីដេអូទៅលើសកម្មភាពបូមខ្សាច់ដែល សង្ស័យថាខុសច្បាប់។[71]

39. នៅដើមខែតុលា ក្រសួងមហាផ្ទៃ បានចេញសេចក្តីណែនាំរដ្ឋបាលមួយ ដែលលើសពីលក្ខខណ្ឌនៅក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដោយតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលនិងសមាគមផ្សេងៗ ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន ចំនួនបីថ្ងៃមុនធ្វើសកម្មភាពទាំងអស់។[72] ទង្វើនេះ បានប៉ះពាល់ដោយផ្ទាល់ទៅលើសកម្មភាពប្រចាំថ្ងៃ ជាពិសេស ដោយសារតែមានវត្តមានប៉ូលីសច្រើនឡើង មុននិងអំឡុងពេលធ្វើសកម្មភាពឬ

---

[67] End of Mission Statement, 18 August 2017, https://www.OHCHR.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=22046&LangID=E

[68] https://www.rfa.org/khmer/news/politics/A-youth-ngo-call-on-people-to-protest-against-ressolving-cnrp-10272017030538.html

[69] https://cchrcambodia.org/media/files/press_release/679_212pcrifappafcthe_en.pdf

[70] http://cambodia.OHCHR.org/en/news/cambodia-un-special-rapporteur-calls-restoration-democracy-and- vibrant-civil-society

[71] A/HRC/37/64, para 8. They were subsequently convicted and received one-year prison sentences, with seven months suspended.

[72] A/HRC/39/73, para 7

រៀបចំព្រឹត្តិការណ៍នានា។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស មិនត្រឹមតែកត់សម្គាល់ឃើញមានការកើនឡើងនៃការរាយការណ៍ អំពីការបំភិតបំភ័យដល់អង្គការសង្គមស៊ីវិល និងបណ្តាលឲ្យបុគ្គលិកមានការភ័យខ្លាចទេ[73] សូម្បីតែសកម្មភាពរបស់ OHCHR ក៏រងផលប៉ះពាល់ ដោយសារតែអាជ្ញាធរអនុវត្តតាមសេចក្តីណែនាំនោះដែរ។

### (c) ប្រព័ន្ធផ្សព្វផ្សាយ

40. ក្នុងខែសីហា ឆ្នាំ២០១៧ រដ្ឋាភិបាលបានលុបចោលឬព្យួរអាជ្ញាប័ណ្ណស្ថានីយ៍វិទ្យុឯករាជ្យ យ៉ាងហោចណាស់ចំនួន១៩ ដែលផ្សព្វផ្សាយពាសពេញផ្ទៃប្រទេស ហើយដែលភាគច្រើនចាក់ផ្សាយកម្មវិធីរបស់គណបក្សសង្គ្រោះជាតិ កម្មវិធីសម្លេងប្រជាធិបតេយ្យ វិទ្យុអាស៊ីសេរី និងវិទ្យុសម្លេងសហរដ្ឋអាមេរិច។ ក្រោយមក ការិយាល័យវិទ្យុអាស៊ីសេរីនៅភ្នំពេញត្រូវបានបិទដោយសារតែបញ្ហាអាជ្ញាប័ណ្ណ/ពន្ធអាករ។ កាសែតឌឹខេមបូឌាដេលី ដែលជាកាសែតឯករាជ្យចេញផ្សាយប្រចាំថ្ងៃជាភាសាអង់គ្លេស ក៏ត្រូវបានបង្ខំឲ្យបិទ បន្ទាប់ពីទទួលបានវិក័យប័ត្រត្រូវបង់ពន្ធលើទឹកប្រាក់ចំនួន ៦.៣លានដុល្លារ។[74] គេហទំព័រថ្មីដែលប្រតិបត្តិការពីក្រៅប្រទេសរបស់កាសែតនេះ បច្ចុប្បន្ននេះ ត្រូវបានរាំងខ្ទប់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណែតនៅក្នុងប្រទេសកម្ពុជាដែរ។[75]

41. សម្លេងប្រព័ន្ធផ្សព្វផ្សាយមួយក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយចុងក្រោយ គឺកាសែតភ្នំពេញប៉ុស្តិ៍ បានទទួលការទាមទារឲ្យបង់ពន្ធចំនួន ៣,៩លានដុល្លា។ មានការរាយការណ៍ថាការទាមទារនេះ ត្រូវបានដោះស្រាយ ជាផ្នែកមួយនៃការលក់កាសែតនេះ ទៅឲ្យវិនិយោគិនជនជាតិម៉ាឡេស៊ី កាលពីខែឧសភា ឆ្នាំ២០១៨។ យោងតាមព័ត៌មានដែលទទួលបាន ភាពជានាយករបស់ក្រុមវិនិយោគិនម៉ាឡេស៊ីនេះ ត្រូវបានបញ្ចប់នៅដើមខែកក្កដា និងត្រូវបានជំនួសដោយនាយកប្រតិបត្តិថ្មីមួយរូប ដែលជាសមាជិកក្រុមការងារស្រុកមួយរបស់គណបក្សប្រជាជនកម្ពុជា។ ពីរថ្ងៃក្រោយការលក់ និពន្ធនាយក ត្រូវបានបណ្តេញចេញពីការងារ បន្ទាប់ពីមានជម្លោះមួយជាមួយម្ចាស់ថ្មី ពាក់ព័ន្ធនឹងអត្ថបទមួយដែលកាសែតនេះបានចុះផ្សាយអំពីការលក់និងចំណងទំនាក់ទំនងរវាងម្ចាស់ថ្មីនិងគណបក្សកាន់អំណាចក្នុងប្រទេសកម្ពុជា។ បុគ្គលិកនិងអ្នករាយការណ៍ជាតិនិងអន្តរជាតិជាងដប់នាក់ បានលាឈប់ពីការងារដោយសារតែក្តីបារម្ភទាក់ទងនឹងការជ្រៀតជ្រែកលើការងារបណ្ណាធិការ។

42. ក្នុងខែកញ្ញា ឆ្នាំ២០១៧ អ្នកនាំពាក្យក្រសួងព័ត៌មានបានគំរាមកំហែង ចាប់អ្នករាយការណ៍វិទ្យុអាស៊ីសេរី ដាក់គុក ប្រសិនបើនៅតែបន្តធ្វើការងារនៅក្នុងប្រទេសកម្ពុជា។[76] ពីរខែក្រោយមក អតីតអ្នករាយការណ៍វិទ្យុអាស៊ីសេរីពីរនាក់ គឺលោក អ៊ុន ឈិន និង យៀង សុជារិន ត្រូវបានឃាត់ខ្លួន ដោយសារមូលហេតុថាពួកគេកំពុងបញ្ជូនសេចក្តីរាយការណ៍ព័ត៌មានទៅការិយាល័យវិទ្យុអាស៊ីសេរីនៅក្រៅប្រទេស។ នៅទីបំផុត បុរសទាំងពីរនាក់ត្រូវបាន

[73] A/HRC/37/64, para 9

[74] A/HRC/39/73, para 64; KHM 4/2017, https://spcommreports.OHCHR.org/TMResultsBase/DownLoadPublicCommunicationFile?gId=23326

[75] https://www.cambodiadaily.com

[76] https://www.phnompenhpost.com/national/official-warns-ex-rfa-staffers-about-continuing-work- cambodia; https://www.voacambodia.com/a/cambodia-threatens-radio-free-asia-journalists-with- arrest/4035393.html

ចោទប្រកាន់ពីបទចារកម្ម និងជាប់ពន្ធនាគាររងចាំការជំនុំជម្រះក្តី។ ក្នុងខែតុលា ២០១៧ អ្នកាសែតឃែមបូឌាដេលីពីរនាក់ ត្រូវបានចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ពាក់ព័ន្ធនឹងការយកព័ត៌មានទាក់ទងនឹងការបោះឆ្នោត កាលពីខែឧសភា។

## (d) អ្នកជំទាស់ជាបុគ្គល

43. មានការឃ្លាំមើលនិងការបង្ក្រាបដែលបានកើតឡើងជាហូរហែ ទៅលើសកម្មភាពរិះគន់រដ្ឋាភិបាល នៅតាមប្រព័ន្ធអ៊ីនធឺណែត។[77] លក្ខណៈពិសេសមួយ គឺការឃុំខ្លួននិងការជំនុំជម្រះទៅលើបុគ្គលដែលគេចាត់ទុកថាបានប្រមាថទៅលើលោកនាយករដ្ឋមន្ត្រី។ ឧទាហរណ៍ បុរសម្នាក់អាយុ២៩ឆ្នាំ ត្រូវបានមន្ត្រីប៉ូលីសយោធាចាប់ខ្លួន នៅខេត្តកំពង់ចាមកាលពីខែកុម្ភៈ ឆ្នាំ២០១៨ បន្ទាប់ពីមានការរាយការណ៍ថា គាត់បានហៅរដ្ឋាភិបាលថា ជារដ្ឋាភិបាល "ផ្តាច់ការ" លើ Facebook។ ស្រដៀងគ្នានេះដែរ កម្មករចំណាកស្រុកម្នាក់អាយុ៣៤ឆ្នាំ ត្រូវបានចាប់ខ្លួននៅខេត្តបន្ទាយមានជ័យ កាលពីខែមិនា ឆ្នាំ២០១៨ ពីបទប្រមាថនាយករដ្ឋមន្ត្រីតាម Facebook។ លោកស្រី ហ៊ិន វ៉ាន់ស្រីពៅ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួនមួយឆ្នាំ កាលពីខែមករា ឆ្នាំ២០១៨ និងពិន័យជាទឹកប្រាក់១លានរៀល ពីបទញុះញង់ ដោយសារតែការផ្សាយតាម Facebook ភ្ជាប់នាយករដ្ឋមន្ត្រីទៅនឹងឃាតកម្មលើលោក កែម ឡី។ អ្នករាយការណ៍ពិសេស បានទទួលព័ត៌មានអំពីករណីបែបនេះជាច្រើន។ លក្ខណៈដូចគ្នានៃករណីទាំងនេះ រួមមាន ការចាប់ខ្លួនដោយគ្មានដីកា និងការចោទប្រកាន់ពីបទប្រមាថជាសាធារណៈ/បរិហារកេរ្តិ៍ ហើយជួនកាលមានបន្ថែមបទញុះញង់។

44. គណៈកម្មាធិការសិទ្ធិមនុស្សបានកត់សម្គាល់ថា "ទង្វើនៃទម្រង់សម្តែងមតិដែលចាត់ទុកជាការប្រមាថដល់បុគ្គលសាធារណៈបែបនេះ មិនមានភាពគ្រប់គ្រាន់ក្នុងការផ្តល់យុត្តិកម្មសម្រាប់ការដាក់ទណ្ឌកម្មនោះទេ" ។[78] បុគ្គលសាធារណៈទាំងអស់ ដោយរួមទាំងប្រមុខរដ្ឋនិងរដ្ឋាភិបាលផងនោះ គឺជាប្រធានបទនៃ ការរិះគន់និងការជំទាស់ផ្នែកនយោបាយ។ ដោយសារតែលក្ខណៈនៃតួនាទីរបស់ខ្លួន មន្ត្រីសាធារណៈ គួរមានភាពអត់ធ្មត់ច្រើនជាងពលរដ្ឋធម្មតាចំពោះការរិះគន់ជាសាធារណៈ ។

45. ក្នុងខែមិនា ឆ្នាំ២០១៨ បទប្បញ្ញត្តិអំពី "ការប្រមាថព្រះមហាក្សត្រ" ត្រូវបានដាក់ចូលក្នុងច្បាប់ប្រទេសកម្ពុជា។[79] ការអំពាវនាវរបស់គណបក្សសង្គ្រោះជាតិ ទៅកាន់ព្រះមហាក្សត្រដើម្បីអន្តរាគមន៍ បានកើតឡើងជាញឹកញាប់នៅក្នុងពេលចលាចលនយោបាយក្រោយការបោះឆ្នោតឆ្នាំ២០១៣។ តួនាទីរបស់ព្រះអង្គ ត្រូវបានអំពាវនាវទៀត បន្ទាប់ពីការរំលាយគណបក្សសង្គ្រោះជាតិ។ តាមរយៈបទប្បញ្ញត្តិថ្មីនោះ សុន្ទរកថា កាយវិការ ការសរសេរ គំនូរ ឬ របស់របរ ដែល "ប៉ះពាល់សេចក្តីថ្លៃថ្នូរ" របស់ព្រះមហាក្សត្រ អាចដាក់ទណ្ឌកម្មជាប់ពន្ធនាគាររហូតដល់៥ឆ្នាំ និងអាចពិន័យជាប្រាក់រហូតដល់១០លានរៀល (២៥០០ ដុល្លារ)។ អង្គការដែលរកឃើញថាមានទោស អាចត្រូវរំលាយ ដាក់ក្រោមការត្រួតពិនិត្យរបស់តុលាការ ហាមឃាត់មិនឲ្យអនុវត្តសកម្មភាព បិទចោល ឬត្រូវរឹបអូសមូលនិ

[77] The same rights that people have offline must be protected online, including the right to privacy, General Assembly resolution A/RES/68/167 para 3. See also A/HRC/RES/38/7, para 1

[78] CCPR/C/GC/34, Para 38

[79] KHM 1/2018, https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=23660

ធិនិងទ្រព្យសម្បត្តិ។ បទប្បញ្ញត្តិបែបនេះ មិនស្របនឹងកាតព្វកិច្ចរបស់ប្រទេសកម្ពុជា ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិទេ ដោយសារតែបទប្បញ្ញត្តិទាំងនេះ ចាត់ទុកការប្រើប្រាស់សេរីភាពបញ្ចេញមតិ ជាបទល្មើសព្រហ្មទណ្ឌ។[80]

46. មានការរាយការណ៍អំពីការចាប់ខ្លួនមនុស្សយ៉ាងហោចណាស់បីនាក់ ក្រោមបទប្បញ្ញត្តិថ្មីនេះ។ បន្ថែមលើនេះ លោក សម រង្ស៊ី ត្រូវបានតុលាការក្រុងភ្នំពេញ កោះហៅ កាលពីខែមិថុនា ឆ្នាំ២០១៨ បន្ទាប់ពីការផ្សាយតាម Facebook របស់គាត់ដែលបានអះអាងថា លិខិតរបស់ព្រះមហាក្សត្រដែលអំពាវនាវឲ្យប្រជាជនទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត ជាលិខិតក្លែងក្លាយឬចេញដោយការបង្ខិតបង្ខំ។[81]

47. បទចោទញុះញង់ ក៏ត្រូវបានប្រើច្រើន សម្រាប់សកម្មភាពក្រៅពីប្រព័ន្ធអ៊ីនធឺណែតដែលចាត់ទុកថាជាការរិះគន់ទៅលើរដ្ឋាភិបាល។ ក្នុងពាក់កណ្ដាលខែវិច្ឆិកា ឆ្នាំ២០១៧ កសិករម្នាក់អាយុ៤៧ឆ្នាំ មកពីខេត្តព្រៃវែងត្រូវបានឃាត់ខ្លួន ពីបទចែកចាយខិត្តប័ណ្ណនៅក្នុងទីក្រុងភ្នំពេញ ដែលមានខ្លឹមសារប្រឆាំងនឹងការរំលាយគណបក្សសង្គ្រោះជាតិ។ ប៉ុន្មានថ្ងៃមុននោះដែរ បុរសម្នាក់ទៀតអាយុ៤៤ឆ្នាំ ត្រូវបានឃុំខ្លួន នៅទីក្រុងភ្នំពេញ ពីបទចែកចាយលិខិត "ញុះញង់" ប្រឆាំងរដ្ឋាភិបាល និងប្រឆាំងនាយករដ្ឋមន្ត្រី។

### (e) បាតុករ

48. ការរឹតត្បិតសេរីភាពជួបជុំកាលពីខែមករា ឆ្នាំ២០១៤ មិនទាន់ត្រូវបានដកចេញជាផ្លូវការនៅឡើយទេ។ អ្នករាយការណ៍ពិសេសមុនខ្ញុំ សោកស្ដាយដែលអាជ្ញាធរកម្ពុជាមិនបានយល់ថា សេរីភាពបញ្ចេញមតិនិងការតវ៉ាដោយសន្តិវិធី គឺជាចំណែកដែលជាប់មកជាមួយដំណើរការលទ្ធិប្រជាធិបតេយ្យ ដែលគួរតែទទួលបានការសម្រួលនិងមិនគួររារាំងទេ។[82] អ្នករាយការណ៍ពិសេសបានកត់សម្គាល់ពីមុនមកហើយថា ជាធម្មតា កងកម្លាំងសន្តិសុខ បដិសេធការជូនដំណឹងអំពីការជួបជុំ និងប្រើរបាំងផ្លូវ ដើម្បីទប់ស្កាត់និងរារាំងការជួបជុំដោយសន្តិវិធី។[83] សកម្មភាពបែបនេះ នៅតែបន្តកើតមាន ជាពិសេស នៅពេលមានភាពតានតឹងជុំវិញការរំលាយគណបក្សសង្គ្រោះជាតិ និងការភ័យខ្លាច "បដិវត្តពណ៌"។

49. មានព័ត៌មានអាចទុកចិត្តបានអំពីករណីដែលប៉ូលីសប៉ុនប៉ងរារាំងបាតុកម្ម ឬការប្រមូលផ្ដុំដើម្បីគាំទ្រគណបក្សសង្គ្រោះជាតិ។ អាជ្ញាធរបានហាមឃាត់រាល់ការប្រមូលផ្ដុំនិងការតវ៉ានានា នៅថ្ងៃជំនុំជម្រះក្ដីលោក កឹម សុខា ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ ហើយផ្លូវទាំងអស់ដែលឆ្ពោះទៅតុលាការកំពូល ត្រូវបានដាក់របាំង។ ក្នុងករណីមួយផ្សេងទៀត ប៉ូលីសក្នុងខេត្តកោះកុង បានរារាំងអ្នកលក់ដូរម្នាក់ មិនឲ្យទៅទីក្រុងភ្នំពេញ ដើម្បីទប់ស្កាត់មិនឲ្យគាត់ទៅចូលរួមបាតុកម្មគាំទ្រគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧។ ស្រដៀងគ្នានេះដែរ សមាជិកក្រុមប្រឹក្សាឃុំអតីតគណបក្សសង្គ្រោះជាតិ ត្រូវបានកោះហៅទៅសាកសួរនៅទីតាំងប៉ូលីសក្នុងខេត្តបាត់ដំបង ក្នុងខែកុម្ភៈ ឆ្នាំ២០១៨ បន្ទាប់ពីគាត់បាន

80 https://www.OHCHR.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=22674&LangID=E

81 https://www.khmertimeskh.com/50502935/sam-rainsy-summoned-for-insulting-the-king/

82 Oral statement at the HRC, Sep. 2013, cf. FN 33

83 A/HRC/36/61, para 46

ចូលរួមព្រឹត្តិការណ៍សប្បុរសធម៌របស់មិត្តភក្តិគាត់នៅក្នុងភូមិ គឺថា ប៉ូលីសបានចោទគាត់ថា រៀបចំការប្រមូលផ្តុំដោយមិនបានជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន និងបានអះអាងថា គាត់កំពុងព្យាយាមបង្កើតចលនាផ្តួលរំលំរដ្ឋាភិបាល។

50. នៅថ្ងៃទី២៧ ខែមិនា នៅពេលដែលលោក កឹម សុខា ត្រូវបង្ហាញខ្លួនក្នុងសវនាការនៅសាលាឧទ្ធរណ៍ កងកម្លាំងសន្តិសុខបានរារាំង និងដាក់របាំងនៅតាមផ្លូវក្បែរសាលាឧទ្ធរណ៍ ដើម្បីឲ្យអ្នកតវ៉ានៅឲ្យឆ្ងាយ។ អ្នកគាំទ្រអតីតគណបក្សសង្គ្រោះជាតិមួយចំនួន បានប្រមូលផ្តុំដោយសន្តិវិធីនៅជិតរបាំងផ្លូវទាំងនោះ ហើយមានម្នាក់បានយកដីស គូសនិមិត្តសញ្ញានៅលើផ្លូវ។ មន្ត្រីសន្តិសុខខណ្ឌម្នាក់បានទះកំភ្លៀងគាត់ ហើយបាតុកម្មដោយសន្តិវិធីនោះ ត្រូវបានបំបែក។ ក្តីបារម្ភអំពី "បដិវត្តពណ៌" មានន័យថា រាល់សកម្មភាពនយោបាយណាមួយដែលជំទាស់នឹងរដ្ឋ ត្រូវទទួលរងការគំរាមកំហែង។ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ សមាជិករណសិរ្សរំដោះជាតិខ្មែរ៥នាក់ ត្រូវប៉ូលីសចាប់ឃុំខ្លួន នៅទីក្រុងភ្នំពេញ ពាក់ព័ន្ធនឹងផែនការចែកខិត្តប័ណ្ណដែលអំពាវនាវឲ្យប្រជាជនតវ៉ាប្រឆាំងនឹងរដ្ឋាភិបាល ក្នុងអំឡុងពេលបុណ្យអុំទូក។ សូម្បីតែកម្មករចំណាកស្រុកកម្ពុជាដែលគាំទ្រគណបក្សសង្គ្រោះជាតិ ធ្វើការតវ៉ានៅក្នុងប្រទេសសាធារណរដ្ឋកូរ៉េ ក៏ត្រូវអគ្គរាជទូតកម្ពុជា គំរាមកំហែងថានឹងមានហានិភ័យទាក់ទងនឹងបណ្តឹងតាមផ្លូវច្បាប់នៅពេលវិលត្រឡប់ទៅផ្ទះវិញដែរ។[84]

51. មានការទទួលបានព័ត៌មានអំពី ការរារាំងការធ្វើបាតុកម្មដែលមិនមានចរិកនយោបាយ តាមរបៀបផ្សេងៗ។ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា បានជូនដំណឹងដល់សាលារាជធានីភ្នំពេញអំពីគោលបំណងក្នុងការប្រមូលផ្តុំមនុស្សចំនួន២៥០នាក់ នៅជិតវត្តភ្នំនៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ ដែលជា "ទិវាគ្រូបង្រៀន" និងដង្ហែក្បួនឆ្ពោះទៅក្រសួងអប់រំ និងខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដើម្បីដាក់ញត្តិ។ មួយថ្ងៃមុនព្រឹត្តិការណ៍នេះ សមាគមបានទទួលដំណឹងថា មិនអនុញ្ញាតឲ្យមានការប្រមូលផ្តុំទេ ដោយមានលើកឡើងនូវមូលហេតុសុវត្ថិភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ស្រដៀងគ្នានេះដែរ ការជូនដំណឹងរបស់សហភាពការងារកម្ពុជា ដើម្បីរៀបចំទិវាពលកម្ម ក្នុងឆ្នាំ២០១៨ ដោយមានការដង្ហែក្បួនកម្មករចំនួន២០០០នាក់ មិនត្រូវបាន សាលារាជធានីភ្នំពេញអនុញ្ញាតឡើយ។ ពួកគេត្រូវបានអនុញ្ញាតឲ្យរៀបចំ នៅនឹងកន្លែងតែប៉ុណ្ណោះ។

## V. ការបោះឆ្នោតថ្នាក់ជាតិ ២០១៨

52. ការរំលាយគណបក្សសង្គ្រោះជាតិ និងការហាមឃាត់អ្នកនយោបាយជាន់ខ្ពស់ចំនួន ១១៨នាក់ ពីសកម្មភាពនយោបាយ កាលពីខែវិច្ឆិកា ធ្វើឲ្យមានការលើកឡើងនូវសំណួរធ្ងន់ធ្ងរមួយចំនួន អំពីថាតើ ការបោះឆ្នោតសភាជាតិឆ្នាំ២០១៨ អាចជាការបោះឆ្នោតពិតប្រាកដដែរឬទេ។[85] ទិដ្ឋភាពមួយចំនួនអំឡុងពេលឈានទៅដល់ថ្ងៃបោះឆ្នោត ក៏ជាបុព្វហេតុនៃក្តីបារម្ភបន្ថែមទៀតដែរ ជាពិសេស វិធានការចំពោះការអំពាវនាវធ្វើពហិកាការបើឆ្នោត នៅក្នុងស្ថានភាពមួយដែលការទៅបោះឆ្នោត មិនមែនជាកាតព្វកិច្ច ក៏ដូចជាការរាយការណ៍អំពីការ

[84] https://bit.ly/2vNpYxl

[85] https://www.OHCHR.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=23009&LangID=E; https://www.OHCHR.org/EN/NewsEvents/Pages/DisplayNews.aspx?LangID=E&NewsID=22406

បំភិតបំភ័យទៅលើអ្នកបោះឆ្នោត និងអង្គការសង្គមស៊ីវិល និងការត្រួតត្រាទៅលើប្រព័ន្ធផ្សព្វផ្សាយ។

## A. ប្រតិកម្មតបនឹងការអំពាវនាវឲ្យធ្វើពហិការ

53. នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៨ លោក សម រង្ស៊ី បានចែករំលែកនៅលើទំព័រ Facebook របស់គាត់ នូវវីដេអូសម្ភាសជាមួយវិទ្យុអាស៊ីសេរី ដែលគាត់បានអំពាវនាវដល់ប្រជាជនកម្ពុជា ដែលជឿលើលទ្ធិប្រជាធិបតេយ្យឲ្យធ្វើពហិការកុំទៅបោះឆ្នោតនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ប្រសិនបើគណបក្សសង្គ្រោះជាតិ មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងការបោះឆ្នោតនោះ។[86] គាត់ក៏បានអំពាវនាវដល់អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ ឲ្យដកខ្លួនចេញពី "ការសង្កេតការណ៍" ការបោះឆ្នោតនោះ។ គាត់បានអំពាវនាវបែបនេះ ម្តងហើយម្តងទៀត។

54. នៅថ្ងៃទី៤ ខែឧសភា លោកនាយករដ្ឋមន្ត្រី បានចាត់ទុកការអំពាវនាវក្នុងការធ្វើពហិការនេះ ថាជាអំពើខុសច្បាប់ ដែលរំលោភបំពានទៅលើមាត្រា១៤២ នៃច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រ។[87] ថ្នាក់ដឹកនាំរបស់ គ.ជ.ប ក៏ធ្វើសេចក្តីថ្លែងការណ៍ស្រដៀងគ្នានេះដែរ ដោយក្នុងនោះ អ្នកនាំពាក្យ បានភ្ជាប់ការអំពាវនាវឲ្យធ្វើពហិការ ទៅនឹងការញុះញង់ និងការបង្កើតឲ្យមានចលាចល។[88]

55. នៅថ្ងៃទី២ ខែឧសភា បន្ទាប់ពីលោក សម រង្ស៊ី ចេញខិត្តប័ណ្ណតាមប្រព័ន្ធអ៊ីនធឺណែតអំពាវនាវឲ្យធ្វើពហិការមក អគ្គលេខាធិការរង គ.ជ.ប បានបញ្ជាក់សារជាថ្មីម្តងទៀតថា នឹងមានការចាត់វិធានការ មិនត្រឹមតែទៅលើលោក សម រង្ស៊ី ទេ គឺថែមទាំងចាត់វិធានការទៅលើរាល់បុគ្គលណាដែលចែកផ្សាយខិត្តប័ណ្ណនោះ ទោះជាធ្វើឡើងជាបុគ្គលឬតាមប្រព័ន្ធអ៊ីនធឺណែតក៏ដោយ។[89] បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ព្រមានអំពីការចែករំលែកខិត្តប័ណ្ណរួចមក នៅថ្ងៃទី៧ ខែឧសភា អ្នកនាំពាក្យមួយរូបពីក្រសួងមហាផ្ទៃ បានបន្ថែមថា ពួកគេក៏នឹងចាត់វិធានការទៅលើរាងពុម្ពណាដែលបោះពុម្ពខិត្តប័ណ្ណទាំងនោះដែរ។[90]

56. នៅថ្ងៃទី៨ ឧសភា ប្រធាន គ.ជ.ប បានសរសេរលិខិតទៅក្រសួងមហាផ្ទៃ ដោយស្នើឲ្យចាត់វិធានការផ្លូវច្បាប់ ដោយមូលហេតុថា ការអំពាវនាវឲ្យធ្វើពហិការ កំពុងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនិងសន្តិសុខជាតិតាមរយៈការរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឲ្យទៅបោះឆ្នោត និងបង្កឲ្យមានការភ័ន្តច្រឡំ ដែលនាំឲ្យមានការបាត់បង់ភាពជឿជាក់នៅក្នុងការបោះឆ្នោត។[91] ឧបនាយករដ្ឋមន្ត្រី បានប្រដូចការអំពាវនាវឲ្យធ្វើពហិការនេះ ទៅនឹងការញុះញង់ ឬរារាំងពលរដ្ឋមិនឲ្យទៅបោះឆ្នោត ដែលនេះជាទង្វើខុសច្បាប់។[92] ស្រដៀងគ្នានេះ

---

[86] https://www.facebook.com/rainsy.sam.5/videos/1790133781043347/?t=19

[87] Facebook post on file, https://www.khmertimeskh.com/50486675/pm-call-for-election-boycott- illegal/

[88] https://www.khmertimeskh.com/50303075/rainsy-wants-election-boycott-while-hun-sen-touts-peace/

[89] https://www.phnompenhpost.com/national/election-body-threatens-legal-action-over-sam-rainsys- boycott-leaflets

[90] https://www.phnompenhpost.com/national/hun-sen-warns-dispersing-election-boycott-leaflet

[91] Letter no 474 (on file), https://www.khmertimeskh.com/50490768/nec-asks-interior-ministry-to-take- action-against-anyone-calling-for-a-poll-boycott/; https://khmer.voanews.com/a/cambodia-election- body-files-complaint-against-election-boycott-campaigners/4398605.html

[92] https://www.rfa.org/english/news/cambodia/threats-05242018171039.html; https://www.phnompenhpost.com/national/interiors-sar-kheng-seeks-punish-those-calling-election- boycott

ដែរ អគ្គលេខាធិការ គ.ជ.ប បានប្រាប់អ្នកសារព័ត៌មានថា យុទ្ធនាការប្រឆាំងការបោះឆ្នោត គឺជាបទល្មើសឧក្រិដ្ឋ។[93]

57. ជាការពិតដែលថាសកម្មភាពរាំងមិនឲ្យអ្នកមានសិទ្ធិបោះឆ្នោត បានទៅបោះឆ្នោត គឺផ្ទុយទៅនឹងច្បាប់ប្រទេសកម្ពុជា និងរំលោភបំពានទៅលើសិទ្ធិមនុស្សអន្តរជាតិ។ ក៏ប៉ុន្តែ សម្រាប់ការបោះឆ្នោតក្នុងប្រព័ន្ធដែលការបោះឆ្នោតមិនមែនជាកាតព្វកិច្ច ការអំពាវនាវឲ្យមានពហិកាការបោះឆ្នោត ត្រូវបានអនុញ្ញាត តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយសារវាជាទម្រង់នៃការសម្តែងមតិដែលត្រូវទទួលបានការការពារ។ ទោះបីជាសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ អាចរឹតត្បឹតបាននៅក្នុងកាលៈទេសៈមួយចំនួនក៏ដោយ ក៏គណៈកម្មាធិការសិទ្ធិមនុស្ស បញ្ជាក់យ៉ាងច្បាស់ថា ការរឹតត្បឹតចំពោះការអំពាវនាវឲ្យធ្វើពហិកាសម្រាប់ការបោះឆ្នោតដែលមិនមែនជាកាតព្វកិច្ច នេះគឺមិនស្រប ទៅនឹងសិទ្ធិ សេរីភាពក្នុងការបញ្ចេញ មតិ ដោយសារតែការរឹតត្បឹតនេះ បន្ទុកបង្អាក់ដល់ការជជែកវែកញែកផ្នែកនយោបាយ។[94] ការជំរុញឲ្យអ្នកបោះឆ្នោតធ្វើពហិកា គួរត្រូវបានបែងចែកឲ្យដាច់ពីការបំភិតបំភ័យនិងការបង្ខំ ហើយការដែលនរណាម្នាក់បង្ហាញចេតនាក្នុងការមិនទៅបោះឆ្នោត មិនប៉ះពាល់ដល់លទ្ធភាពរបស់អ្នកបោះឆ្នោត ក្នុងការសម្រេចចិត្តដោយសេរី ថាតើពួកគេទៅឬមិនទៅបោះឆ្នោតនៅក្នុងការបោះឆ្នោតណាមួយនោះទេ។[95]

## B. ការបំភិតបំភ័យនិងការយីយារំខានអ្នកបោះឆ្នោត

58. អ្នករាការណ៍ពិសេស មានការព្រួយបារម្ភចំពោះរបាយការណ៍អំពីវិធានការរបស់អាជ្ញាធរកម្ពុជា ដែលប៉ះពាល់ដល់បុគ្គលដែលជាអ្នកបោះឆ្នោត ជាពិសេស អ្នកដែលកំពុងពិចារណាក្នុងការមិនទៅបោះឆ្នោត។ ឧទាហរណ៍ អភិបាលខេត្តរតនៈគីរី បានអំពាវនាវដល់អាជ្ញាធរខេត្ត ឲ្យចាត់វិធានការទៅលើបុគ្គលដែលញុះញង់ប្រជាជនឲ្យធ្វើពហិកាមិនទៅបោះឆ្នោត ដោយផ្សារភ្ជាប់បញ្ហានេះទៅនឹងការរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ។[96] អគ្គស្នងការរងនគរបាលជាតិ ដែលជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនកម្ពុជា បានណែនាំដល់សមាជិកទាំងអស់របស់គណបក្សប្រជាជនកម្ពុជា ឲ្យតាមដានក្នុងសហគមន៍របស់ខ្លួន និងរាយការណ៍អំពីជនដែលប្រាប់អ្នកដទៃមិនឲ្យទៅបោះឆ្នោត។[97] ប្រព័ន្ធផ្សព្វផ្សាយក៏បានរាយការដោយដកស្រង់សម្តីរបស់មន្ត្រីថ្នាក់ភូមិ ថាស្ថិតនៅក្រោមការណែនាំ ឲ្យតាមដានអ្នកបោះឆ្នោតនៅក្នុងភូមិនិងធ្វើយ៉ាងណាឲ្យពួកគេទៅបោះឆ្នោត។[98]

59. ព័ត៌មានពីបុគ្គលជាអ្នកបោះឆ្នោត ក៏បានលើកឡើងអំពីការបំភិតបំភ័យ។ ឧទាហរណ៍ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៨ មានការរាយការណ៍ថា លោក អ៊ុំ សារ៉ាន់ គ្រូបង្រៀននៅអនុវិទ្យាល័យត្រពាំងចាន់ ក្នុងខេត្តកំពង់ឆ្នាំង និងជាអតីតជំទប់ទីពីឃុំឆ្នុកទ្រូ ត្រូវបានគេឃាត់ខ្លួន ដោយសារមូលហេតុញុះញង់ប្រជាជនមិនឲ្យទៅបោះឆ្នោត។ លិខិតរបស់អ្នក

[93] http://www.dailymail.co.uk/wires/afp/article-5961949/Cambodia-calls-campaign-boycott-election- crime.html

[94] CCPR/C/GC/34, para 28

[95] CCPR/C/81/D/927/2000, para 7.3

[96] https://www.khmertimeskh.com/50492839/curb-calls-not-to-vote-ratanakkiri-governor/

[97] http://www.freshnewsasia.com/index.php/en/localnews/88587-2018-06-02-03-37-48.html

[98] https://www.reuters.com/article/us-cambodia-election-threats/cambodias-rulers-cajole-and-coerce- voters-to-boost-election-turnout-idUSKBN1KF0LQ

ភូមិមួយចំនួន បានចោទថា លោក សាវ៉ាន់ បានប្រាប់មនុស្សពីរបីនាក់ថា ពួកគេមិនចាំបាច់ទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោតទេ គឺអាចនៅផ្ទះបានហើយ។ ទោះបីជាពួកគេទៅបោះឆ្នោតក៏មិនមាននរណាម្នាក់អាចមើលឃើញនៅកន្លែងគូសសន្លឹកឆ្នោតនោះទេ ហើយប្រសិនបើពួកគេចង់គូសលើសន្លឹកឆ្នោតឬមិនគូសនោះ គឺវាអាស្រ័យទៅលើពួកគេទេ។ ការរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ បានដកស្រង់សម្តីរបស់ស្នងការប៉ូលីសខេត្តកំពង់ឆ្នាំង ដែលបាននិយាយថា លោក សាវ៉ាន់ ត្រូវបានដោះលែងនៅថ្ងៃទី៩ ខែកក្កដា បន្ទាប់ពីគាត់បានសន្យាថានឹងបញ្ឈប់សកម្មភាពបែបនេះ។[99] លោក សាវ៉ាន់ បានបដិសេធរាល់ការចោទប្រកាន់ទាំងអស់ ហើយអះអាងថា គាត់គ្រាន់តែនិយាយថា គាត់នឹងមិនទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោតនោះទេ។

60. ករណីមួយទៀតក្នុងខែឧសភា លោក គង់ រ៉ាយ៉ា ដែលជានិស្សិតអាយុ២៧ឆ្នាំ និងអតីតប្រធានបណ្តាញនិស្សិតកម្ពុជា ដែលពីមុនបានទទួលទោសជាប់ពន្ធនាគារចំនួន១៨ខែ ដោយសារតែការផ្សាយតាម Facebook ក្នុងឆ្នាំ២០១៥-២០១៧[100] បានផ្សាយសារតាម Facebook ថាគាត់នឹងមិនទៅបោះឆ្នោតជាដាច់ខាត ប្រសិនបើគាត់មិនចូលចិត្តគណបក្សណាមួយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនោះ។[101] គាត់និយាយថា ការទៅបោះឆ្នោតឬមិនទៅ គឺជាសិទ្ធិរបស់ពលរដ្ឋគ្រប់រូប និងថា គ្មានបុគ្គលណាម្នាក់ឬគណបក្សនយោបាយណាមួយ អាចបង្ខំឬរារាំងនរណាម្នាក់មិនឲ្យសម្រេចចិត្តថាទៅបោះឆ្នោតឬមិនទៅបោះឆ្នោតនោះទេ។ គាត់បានបញ្ជាក់ ថា មិនមានច្បាប់ណាមួយដែលដាក់ទណ្ឌកម្មទៅលើអ្នកមិនទៅបោះឆ្នោតនោះទេ ហើយគាត់បានអំពាវនាវកុំឲ្យប្រជាជនភ័យខ្លាចក្នុងការបញ្ចេញគំនិតទស្សនៈរបស់ខ្លួន។ គាត់រស់នៅក្នុងទីក្រុងភ្នំពេញ ក៏ប៉ុន្តែ ការផ្សាយសារទាំងនេះនៅក្នុង Facebook ធ្វើឡើងនៅពេលដែលគាត់កំពុងស្នាក់នៅផ្ទះគ្រួសាររបស់ប្រពន្ធគាត់ក្នុងខេត្តសៀមរាប។ មិនយូរប៉ុន្មានក្រោយការផ្សាយនោះ មានការរាយការណ៍ថា មន្ត្រីប៉ូលីស បានប្រមូលផ្តុំគ្នានៅខាងក្រៅផ្ទះរបស់គ្រួសារគាត់។ ដើម្បីជៀសវាងគំនាបសង្កត់បន្ថែមទៀតទៅលើគ្រួសារផ្សេងទៀត លោក រ៉ាយ៉ា បានសម្រេចចិត្តត្រឡប់មកក្រុងភ្នំពេញវិញ។ ប៉ូលីសបានតាមគាត់រហូតដល់គាត់ឡើងជិះឡានក្រុង។ មានការរាយការណ៍ថា លោក រ៉ាយ៉ា បានភៀសខ្លួនចេញពីប្រទេសហើយ ប៉ុន្តែគាត់នៅមានការបារម្ភអំពីសុវត្ថិភាពរបស់គ្រួសារគាត់និងគ្រួសារប្រពន្ធរបស់គាត់នៅឡើយ។

61. នៅដើមខែមិថុនា ឆ្នាំ២០១៨ អ្នកគាំទ្រអតីតគណបក្សសង្គ្រោះជាតិ ដែលបច្ចុប្បន្នកំពុងរស់នៅក្រៅប្រទេស បានផ្សាយសារមួយតាម Facebook ថា គាត់នឹងមិនទៅបោះឆ្នោតទេ។ ពីរបីថ្ងៃក្រោយមក មន្ត្រីប៉ូលីសបានទៅដល់ផ្ទះរបស់សមាជិកគ្រួសាររបស់គាត់ផ្សេងៗគ្នា ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងសាកសួរនៅផ្ទះឬនៅទីតាំងប៉ូលីស អំពីកន្លែងដែលគាត់ស្នាក់នៅ។ សមាជិកគ្រួសារទាំងនេះ បានរាយការណ៍ថា ការឃាឃីវខានពីប៉ូលីស បន្តកើតមានរាប់សប្តាហ៍ក្រោយមកទៀត។ ក្នុងករណីមួយផ្សេងទៀត នៅពេលដែលអ្នកប្រើប្រាស់ Facebook ម្នាក់ និយាយថា គាត់នឹងមិនទៅបោះឆ្នោតក្នុងការបោះឆ្នោតខាងមុខទេនោះ អ្នកនាំពាក្យក្រសួងយុត្តិធម៌ បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា អាជ្ញាធរ

---

[99] http://www.freshnewsasia.com/index.php/en/localnews/92455-2018-07-10-07-16-19.html

[100] KHM 1/2016, https://spcommreports.OHCHR.org/TMResultsBase/DownLoadPublicCommunicationFile?gId=13372

[101] https://www.facebook.com/photo.php?fbid=1586059918186847&set=a.321587721300746.107; https://www.facebook.com/photo.php?fbid=1586838424775663&set=a.321587721300746.107

នឹងពិន័យបុគ្គលនោះ ព្រមទាំងអាចមានការដាក់ទោសទណ្ឌបន្ថែមនិងអប់រំឡើងវិញ។[102]

62. បន្ថែមលើករណីខាងលើនោះ ក៏មានការទទួលបានព័ត៌មានដែលទុកចិត្តបាន ពាក់ព័ន្ធនឹងឧបទ្ទវហេតុផ្សេងទៀត អំពីការដែលអាជ្ញាធរថ្នាក់ឃុំនិងភូមិ យីយាំខាននិងបំភិតបំភ័យបុគ្គលនានា ដើម្បីធ្វើយ៉ាងណាឲ្យពួកគេទៅបោះឆ្នោត។ ក្នុងករណីមួយនៅខេត្តបាត់ដំបង សមាជិកគណបក្សប្រជាជនកម្ពុជា បានដាក់បណ្តឹងមួយទៅកាន់គណៈកម្មការបោះឆ្នោតឃុំ នៅថ្ងៃទី២៥ ខែកក្កដា ប្រឆាំងនឹងអតីតសមាជិកគណបក្សសង្គ្រោះជាតិ ដោយសារតែការចែករំលែកការផ្សាយតាម Facebook ដែលបង្ហាញរូបថត "ម្រាមដៃស្អាត"។ ពីរថ្ងៃក្រោយមក មានការរាយការណ៍ថា មេភូមិបានហៅប្រពន្ធរបស់បុរសម្នាក់នោះ ដើម្បីមកប្រាប់ថាឲ្យទៅបោះឆ្នោត ដើម្បីកុំឲ្យគេមកចាប់ប្តីរបស់នាង។ មានការលើកឡើងច្រើនជាង ១០ករណី ដែលអ្នកគាំទ្រឬសមាជិកអតីតគណបក្សសង្គ្រោះជាតិ ត្រូវបានបង្ខំឲ្យភៀសខ្លួនចេញពីផ្ទះក្នុងខែកក្កដា ដោយសារតែមានការគំរាមកំហែង។ ករណីបន្ថែមមួយចំនួនទៀតក៏ត្រូវបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដែរ។[103]

63. សេចក្តីរាយការណ៍ផ្សេងទៀតរួមមានមន្ត្រីដែលបានអះអាងថា ការបោះឆ្នោតជាកាតព្វកិច្ចដាច់ខាត និងថា បុគ្គលណាដែលមិនទៅបោះឆ្នោតនឹងត្រូវជាប់ពន្ធនាគារ។ ករណីមួយចំនួន មានការផ្សព្វផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយ ដោយរួមមានទាំងការរាយការណ៍មួយពីឃុំព្រែកឫស្សី ខេត្តស្ទឹងត្រែង ដែលអ្នកភូមិបានប្រាប់អ្នកសារព័ត៌មានថា អាជ្ញាធរមូលដ្ឋានបានគំរាមកំហែងនឹងពិន័យជាទឹកប្រាក់ ៣០០.០០០ និង ៣៥០.០០០រៀល (៧៥ និង ៨៧ ដុល្លារ) ទៅលើអ្នកមិនទៅបោះឆ្នោត។[104] មានការរាយការណ៍អំពីការគំរាមកំហែងថា អាជ្ញាធរមូលដ្ឋាននឹងបង្កការលំបាកសម្រាប់អ្នកបោះឆ្នោត ក្នុងការទទួលបានសំបុត្រកំណើត ឬសំបុត្រមរណភាព និងសេវាមូលដ្ឋានដទៃទៀត ប្រសិនបើពួកគេមិនទៅបោះឆ្នោតឲ្យគណបក្សកាន់អំណាច ដោយរបាយការណ៍បែបនេះមួយចំនួន បានផ្ញើដោយផ្ទាល់ទៅកាន់អ្នករាយការណ៍ពិសេស និងរបាយការណ៍ផ្សេងទៀត មានផ្សព្វផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។[105]

64. គេហទំព័រជាច្រើនភាសាជាហូរហែអំពីការដាក់ទោសទណ្ឌ ដែលបានលើកឡើងដូចខាងលើនេះ ដោយរួមបញ្ចូលទាំងការព្រមានរបស់ គ.ជ.ប ផងដែរនោះកាន់តែធ្វើឲ្យអ្នកបោះឆ្នោតមានការភ័យខ្លាច និងមានភាពមិនច្បាស់លាស់។ មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាខ្លះ បានអះអាងថា អ្នកដែលគ្មានស្នាមទឹកខ្មៅនៅលើម្រាមដៃនៅពេលក្រោយការបោះឆ្នោត នឹងត្រូវគេសម្គាល់យ៉ាងងាយថាជាអ្នកគាំទ្រពួកឧទ្ទាមឬជនក្បត់ជាតិ។[106] ទោះជានៅក្នុងសុន្ទរកថាមួយ លោកនាយករដ្ឋមន្ត្រីពិតជាមានប្រសាសន៍ថា នឹងមិនមានការដាក់ទោសទណ្ឌណាមួយសម្រាប់អ្នកដែលមិនបានទៅបោះឆ្នោតក៏ដោយ ប៉ុន្តែ ទន្ទឹមគ្នាដែរនោះ គាត់ក៏បានគំរាមកំហែងដាក់ពន្ធនាគារ សម្រាប់អ្នកដែល "បន្លំ" ជ្រលក់ទឹកថ្នាំលើម្រាមដៃដោយខ្លួន

[102] https://www.voacambodia.com/a/police-hunt-for-facebook-user-calling-for-election-boycott/4440774.html; https://www.phnompenhpost.com/national/police-warn-boycott-fb-group- involved-clean-fingers-campaign

[103] For example https://www.rfa.org/khmer/news/politics/cnrp-in-phnom-proek-flee-from-persecution- 07302018091558.html; https://www.rfa.org/khmer/news/politics/released-cnrp-activists-after- questioning-07292018061837.html

[104] https://www.rfa.org/khmer/news/politics/people-was-threatened-to-vote-07022018042055.html; https://www.reuters.com/article/us-cambodia-election-threats/cambodias-rulers-cajole-and-coerce- voters-to-boost-election-turnout-idUSKBN1KF0LQ

[105] https://www.rfa.org/english/news/cambodia/threats-07172018164210.html

[106] https://www.phnompenhpost.com/national/nonvote-vote-rebels-aids-authority-chief-slams-rainsys- call-boycott-national-elections

ឯង។[107] ដោយមិនទទួលស្គាល់អំពីទំហំនៃការភ័យខ្លាចរបស់ ប្រជាជនកម្ពុជាដែលនាំឲ្យពួកគាត់ហ៊ាន ជ្រលក់ទឹកថ្នាំលើម្រាមដៃដោយខ្លួនឯង ដើម្បីបានរួចផុតពីការដាក់ទោសទណ្ឌក្រោយថ្ងៃបោះឆ្នោតមន្ត្រីរដ្ឋាភិបាល បែរជាជ្រើសយកការចាត់ទុកទង្វើទាំងនោះ ជាសកម្មភាពខុសច្បាប់ ដែលអាចធ្វើឲ្យបុគ្គលទាំងនោះប្រឈមនឹងការជាប់ពន្ធនាគារទៅវិញ។[108] ក្រោយការបោះឆ្នោត គ្រូបង្រៀនពីរនាក់ ត្រូវបានផ្តន្ទាទោសពីបទលួចដបទឹកថ្នាំលុបមិនជ្រះពីមណ្ឌលបោះឆ្នោត ដែលពួកគេប្រចាំការនៅទីនោះ។ មានការរាយការណ៍ថា គ្រូបង្រៀនម្នាក់ បានប្រាប់តុលាការថា លោកស្រីលួចវា យកទៅឲ្យសមាជិកគ្រួសារឬសហការីនៅសាលាជ្រលក់ម្រាមដៃដោយមិនចាំបាច់បោះឆ្នោត ដោយសារមានគេប្រាប់គ្រូទាំងឡាយថា បើមិនទៅបោះឆ្នោត ពួកគាត់នឹងត្រូវគេកាត់ប្រាក់ខែ។[109]

65. ពាក់ព័ន្ធនឹងឧបទ្ទវហេតុទាំងនេះ ព្រមទាំងសេចក្តីថ្លែងការណ៍ដោយតំណាងអាជ្ញាធរកម្ពុជាគ្រប់កម្រិត វាចំបាច់ក្នុងការរំលឹកថាគណៈកម្មាធិការសិទ្ធិមនុស្សបានកត់សម្គាល់ថា "បុគ្គលដែលមានសិទ្ធិបោះឆ្នោត ត្រូវតែមានសេរីភាពក្នុងការបោះឆ្នោតសម្រាប់បេក្ខជនណាមួយសម្រាប់ការបោះឆ្នោត និងមានសេរីភាពក្នុងការបោះឆ្នោតគាំទ្រឬប្រឆាំងនឹងសំណើណាមួយដែលបានដាក់សម្រាប់ការធ្វើប្រជាមតិឬប្រជាសិទ្ធិ ព្រមទាំងមានសេរីភាពក្នុងការគាំទ្រឬជំទាស់នឹងរដ្ឋាភិបាល ដោយគ្មានទទួលរងឥទ្ធិពលឬការបង្ខិតបង្ខំមិនសមរម្យតាមរូបភាពណាមួយ ដែលអាចបង្ខូចឬរារាំងការសម្តែងឆន្ទៈរបស់អ្នកបោះឆ្នោតដោយសេរីឡើយ។ អ្នកបោះឆ្នោត គួរអាចបង្កើតគំនិតទស្សនៈបានដោយឯករាជ្យ មិនមានអំពើហិង្សា ឬការគំរាមកំហែងប្រើអំពើហិង្សា ការដាក់កំហិត ការលួងលោម ឬការជ្រៀតជ្រែកបញ្ឆោតគ្រប់រូបភាព" ។[110]

## C. វិធានការផ្លូវច្បាប់ទៅលើអ្នកបោះឆ្នោត

66. យោងតាមព័ត៌មានទទួលបាន នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ លោក ជា ជីវ សមាជិកអតីតគណបក្សសង្គ្រោះជាតិនៅខេត្តបាត់ដំបង បានអញ្ជើញមិត្តភក្តិនិងអតីតសហការីមួយចំនួន មកជប់លៀងនៅផ្ទះរបស់គាត់នៅឃុំអន្លង់វិល។ បន្ទាប់មក លោក ជា ជីវ បានបង្ហោះរូបថតជាក្រុម តាម Facebook ដោយលើកចង្អុលដៃឡើង និងមានសារថា "ម្រាមដៃរបស់ពួកយើងពិតជាស្អាត"។ ផ្អែកតាមបណ្តឹងរបស់សមាជិកគណបក្សប្រជាជនកម្ពុជាមួយចំនួនដែលបានដាក់ប្តឹងនោះ គណៈកម្មការរៀបចំការបោះឆ្នោតខេត្តបាត់ដំបង បានរកឃើញថា គាត់និងបួននាក់ផ្សេងទៀត មានកំហុសដោយបានរំលោភទៅលើមាត្រា១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ គណៈកម្មការរៀបចំការបោះឆ្នោតខេត្តបានសន្និដ្ឋានថា ការចូលរួមរបស់ពួកគេ ក្នុងការផ្សព្វផ្សាយយុទ្ធនាការ "ម្រាមដៃស្អាត" កំពុងរួមចំណែកដល់ការបង្កឲ្យមានការភ័ន្តច្រឡំ ដែលនាំឲ្យបាត់បង់ការជឿជាក់ទៅលើការបោះឆ្នោត ធ្វើឲ្យអ្នកមានសិទ្ធិបោះឆ្នោតស្ទាក់ស្ទើរក្នុងការទៅបោះឆ្នោត និងមានចេតនា

[107] https://www.phnompenhpost.com/national/pm-dont-stain-election
[108] http://www.freshnewsasia.com/index.php/en/localnews/88296-2018-05-30-02-00-55.html
[109] https://www.khmertimeskh.com/50518185/teachers-convicted-for-stealing-election-ink/
[110] CCPR/C/Rev.1/Add.7, para 19

រារាំងអ្នកមានសិទ្ធិបោះឆ្នោត មិនឲ្យទៅបោះឆ្នោត។[111] មនុស្សទាំងប្រាំនាក់នេះ ត្រូវបានពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន ១០លានរៀល (២៥០០ដុល្លា)។ នៅពេលប្តឹងឧទ្ធរណ៍ គ.ជ.ប បានតម្កល់ការពិន័យលើលោក ជីវ ប៉ុន្តែបានបន្ថយការពិន័យលើមនុស្សពីរនាក់ មកនៅត្រឹម៥លានរៀល (១២៥០ ដុល្លា) និងទំលាក់ចោលការចោទប្រកាន់បុគ្គលពីរនាក់ទៀត។[112] ករណីនេះ ត្រូវបានរាយការណ៍ថា ស្ថិតនៅដំណាក់កាលប្តឹងឧទ្ធរណ៍នៅ គ.ជ.ប។ ជំទប់ទីមួយរបស់គណបក្សប្រជាជនកម្ពុជានៅឃុំអន្លង់វិល បានប្រាប់អ្នកកាសែតថា គាត់ក៏បានដាក់បណ្តឹងស្រដៀងគ្នានេះ ទៅលើអតីតមន្ត្រីគណបក្សសង្គ្រោះជាតិចំនួន២០នាក់ផ្សេងទៀតដែរ។[113] នៅថ្ងៃទី២៥ ខែកក្កដា អ្នកនាំពាក្យក្រសួងមហាផ្ទៃ បាននិយាយថា មានពាក្យបណ្តឹងចន្លោះពី២០ ទៅ ៣០ប្តឹងទៅលើអតីតអ្នកគាំទ្រគណបក្សសង្គ្រោះជាតិក្នុងខេត្តបាត់ដំបងនិងខេត្តក្រចេះ។[114] ស្ថានភាពនៃបណ្តឹងទាំងនោះ មិនត្រូវបានគេដឹងឡើយ។

67. ក្នុងករណីមួយទៀត នៅថ្ងៃទី២៦ ខែកក្កដា គ.ជ.ប បានប្រកាសថា នឹងចាត់វិធានការទៅលើលោក ជួង ជូងី ដែលជាអតីតមេធាវីគណបក្សសង្គ្រោះជាតិ ដែលបានបង្ហោះវីដេអូមួយ ដែលគាត់បានវិភាគច្បាប់ទាក់ទងនឹងការធ្វើពហិការមិនទៅបោះឆ្នោត និងបានធ្វើការសន្និដ្ឋានថា ការអំពាវនាវឲ្យធ្វើពហិកានេះ មិនមានការរំលោភច្បាប់ណាមួយឡើយ។[115] គ.ជ.ប បានរកឃើញថា សកម្មភាពរបស់គាត់ គាំទ្រដល់លោក សម រង្ស៊ី ដែលបានអំពាវនាវឲ្យធ្វើពហិកា ដែលនាំឲ្យមានការភ័ន្តច្រឡំ និងបាត់បង់ការជឿជាក់ក្នុងដំណើរការបោះឆ្នោត។ គេមិនបានដឹងទេថា តើការសម្រេចនេះ មានបានបើកសវនាការឬក៏អត់ទេ ឬថាតើលោក ជួង ជូងី បានធ្វើបទបង្ហាញដើម្បីការពារខ្លួនឯង ឬ ទេ។ គ.ជ.ប បានស្នើក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងព័ត៌មាន ឲ្យបិទគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់លោក ជួង ជូងី, ស្នើឲ្យក្រសួងយុត្តិធម៌ ត្រូវពិនិត្យឡើងវិញ និងចាត់វិធានការទៅលើគាត់ ដោយសារគាត់ត្រូវបានតុលាការកំពូលហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយឡើយ, និងបានស្នើឲ្យគណៈមេធាវី ត្រូវពិនិត្យឡើងវិញ និងចាត់វិធានការទាក់ទងនឹងសកម្មភាពរបស់គាត់ក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោត ដែលបានបង្ហោះតាម Facebook។ មានការរាយការណ៍ថា ក្រសួងយុត្តិធម៌បានបញ្ជូនបញ្ហានេះ ទៅព្រះរាជអាជ្ញាសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការសម្រេចក្នុងការចាត់វិធានការបន្ត។[116]

68. ការអនុវត្តដោយគណៈកម្មការរៀបចំការបោះឆ្នោត ដោយប្រើប្រាស់មាត្រា១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅក្នុងបរិបទនៃការអំពាវនាវឲ្យធ្វើពហិកានេះ បានលើកឡើងនូវក្តីបារម្ភយ៉ាងខ្លាំង។ ខណៈដែលជាតុផ្សំភាគច្រើននៃមាត្រា១៤២ សម្រាប់ដាក់ទោសទណ្ឌទៅលើទង្វើដែលមានការបង្ខិតបង្ខំនោះ ការបកស្រាយក្នុងន័យទូលាយ ទំនងជាជួយរឹតត្បិតទៅលើសិទ្ធិសេរីភាពស្របច្បាប់ក្នុងការសម្តែងមតិ។ បទប្បញ្ញ

111 Decision No. 001 dated 26 July 2018, Battambang Provincial Election Commission

112 https://www.necelect.org.kh/english/sites/default/files/images-attachment/EN_152.jpg. Upheld by the Constitutional Council on 15 August 2018, http://www.ccc.gov.kh/detail_info_kh.php?_txtID=921

113 https://www.khmertimeskh.com/50514898/poll-boycott-callers-pressured-to-apologise/

114 https://www.thmeythmey.com/?page=detail&id=67192

115 https://www.necelect.org.kh/khmer/content/3448

116 https://www.phnompenhpost.com/national/choungy-case-sent-nec-capital-courts

ត្តិជាក់លាក់ចំនួនពីរ គឺ ការបង្កើតការភ័ន្តច្រឡំ ដែលបណ្តាលឲ្យបាត់បង់ទំនុកចិត្តក្នុងការបោះឆ្នោត និងការបង្កើតនូវការបាត់បង់ទំនុកចិត្តទៅលើភាពសម្ងាត់ក្នុងការបោះឆ្នោត ហាក់ដូចជា មានសភាពទូលាយពេក និងមានភាពស្រពេចស្រពិល មិនស៊ីសង្វាក់ជាមួយនឹងភាពច្បាស់លាស់ដែលតម្រូវដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ។

69. គ.ជ.ប ដែលចាត់ទុក ការបង្ហាញរបស់លោក ដូងី ដែលនាំឲ្យមានការភ័ន្តច្រឡំ ឬការបាត់ភាពជឿជាក់ទៅលើដំណើរការបោះឆ្នោតនេះ បានធ្វើឲ្យមានការលើកឡើងនូវសំណួរនៅច្រើនកម្រិត។ គាត់បានបង្ហោះវីដេអូមួយ ដែលផ្តល់នូវការវិភាគផ្លូវច្បាប់ ដែលមានទស្សនៈផ្សេងគ្នាពី គ.ជ.ប និងរដ្ឋាភិបាលកម្ពុជា។ ទោះបីជាទស្សនៈនេះ ខុស ឬ មានភាពមិនល្អឥតខ្ចោះក៏ដោយ ក៏វាត្រូវទទួលបានការការពារដោយសេរីភាពនៃការបញ្ចេញមតិដែរ។ ក៏ប៉ុន្តែ នៅក្នុងឧទាហរណ៍ជាក់លាក់មួយនេះ ការបកស្រាយច្បាប់របស់លោក ដូងី មានភាពស៊ីសង្វាក់គ្នាយ៉ាងពេញលេញជាមួយច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ គ.ជ.ប មិនត្រឹមតែរំលោភបំពានច្បាប់ដោយ ... 

## D. ការត្រួតត្រាប្រព័ន្ធផ្សព្វផ្សាយ ដោយរួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម

70. នៅថ្ងៃទី១២ មិនា ២០១៨ គ.ជ.ប បានដាក់ចេញក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ដែលដកស្រង់ចេញពី "វិធាននិងនីតិវិធីសម្រាប់ការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតីទី៦ និងច្បាប់ស្តីពីការបោះឆ្នោត"។ ក្រមសីលធម៌នេះ ក៏មានបញ្ចូលផ្នែកមួយស្តីពី "ការហាមឃាត់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ" ដែលរួមមាន ការផ្សាយព័ត៌មាន ដែលនាំឲ្យមានការភ័ន្តច្រឡំនិងការបាត់បង់ទំនុកចិត្តក្នុងការបោះឆ្នោត, ការបញ្ចេញទស្សនៈផ្ទាល់ខ្លួននៅក្នុងព្រឹត្តិការណ៍កំពុងកើតឡើង ដែលបានរាយការណ៍, ការបោះផ្សាយឬចាក់ផ្សាយព័ត៌មានដែលប៉ះពាល់ដល់សន្តិសុខជាតិ ស្ថេរភាពនយោបាយនិងសង្គម និងការប្រើប្រាស់ភាសាអុជអាលឬមិនសមរម្យ ដែលអាចបណ្តាលឲ្យមានបាត់បង់សណ្តាប់ធ្នាប់ ឬមានអំពើហិង្សា។[117]

71. ក្រមនេះ ស្រដៀងគ្នាទៅនឹងក្រមដែល គ.ជ.ប បានដាក់ចេញមុនការបោះឆ្នោតមូលដ្ឋានក្នុងឆ្នាំ២០១៧ ដែលនាំឲ្យអ្នករាយការណ៍ពិសេស លើកឡើងនូវក្តីបារម្ភមួយចំនួន។[118] ជាពិសេស វាក្យសព្ទក្នុងសភាពទូលាយ និងមិនជាក់ច្បាស់ ដែលយកមកប្រើ អាចនាំឲ្យមានការរឹតត្បឹតទាំងស្រុងទៅលើប្រព័ន្ធផ្សព្វផ្សាយ ដែលមិនស៊ីសង្វាក់ជាមួយនឹងស្តង់ដារអន្តរជាតិ។[119] អ្នកសារព័ត៌មាន មានការទទួលខុសត្រូវក្នុងការរាយការណ៍បញ្ហាជាច្រើននៅក្នុងអំឡុងពេលឈានដល់ការបោះឆ្នោត ជាពិសេស បញ្ហាដែលមានភាពប្រទាញប្រទង់ ហើយអ្នកសារព័ត៌មាន មិនគួរប្រឈមនឹងការរឹតត្បឹតតាមទំនើងចិត្តនោះទេ។ គណៈកម្មាធិការ សិទ្ធិមនុស្ស បានបញ្ជាក់ថា "ដើម្បីធានាឲ្យទទួលបានសិទ្ធិពេញលេញ ដែលការពារ

[117] https://www.necelect.org.kh/english/sites/default/files/EN-070.pdf

[118] A/HRC/36/61, paras 61-62

[119] https://www.OHCHR.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=23205&LangID=E

ដោយមាត្រា២៥ ការទំនាក់ទំនងព័ត៌មាន និងគំនិតដោយសេរី អំពីបញ្ហាសាធារណៈនិងបញ្ហានយោបាយ រវាងពលរដ្ឋ បេក្ខជន និងតំណាងជាប់ឆ្នោត គឺជាការសំខាន់ណាស់”។[120]

72. នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានអនុម័ត ប្រកាសអន្តរក្រសួងស្ដីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រនិងបណ្ដាញសង្គមដែលដំណើរការតាមរយៈប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា។ ប្រកាសដែលដាក់ជាសាធារណៈ នៅលើគេហទំព័ររបស់ក្រសួងទាំងបីនៅថ្ងៃទី៤ ខែមិថុនា មានគោលបំណងគ្រប់គ្រងការផ្សព្វផ្សាយរាល់ខ្លឹមសារព័ត៌មាន ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀត ដែលមានចេតនាបង្កជាចលាចលបណ្ដាលឲ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃសេដ្ឋកិច្ចជាតិ សណ្ដាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ប្រពៃណីជាតិ។ ក្រសួងទាំងបី បានបញ្ជាក់ថា បានបង្កើតអង្គភាពជំនាញ ដើម្បីតាមដាន សិក្សា និងស្រាវជ្រាវដោយកិច្ចសហប្រតិបត្តិការ ដើម្បីជំរុញឲ្យមានវិធានការផ្លូវច្បាប់ប្រឆាំងនឹងសកម្មភាពអាជីវកម្មនិងការបោះពុម្ពផ្សាយតាមប្រព័ន្ធអ៊ីនធឺណែតខុសច្បាប់។

73. ដើម្បីធ្វើឲ្យច្បាប់ឬបទប្បញ្ញត្តិណាមួយ ស្របជាមួយស្តង់ដារអន្តរជាតិជាធរមានបានបទប្បញ្ញត្តិទាំងនោះ ត្រូវមានការពន្យល់ឲ្យបានច្បាស់លាស់ ជាពិសេស ពាក្យដូចជា "សន្តិសុខជាតិ” "ស្ថេរភាពនយោបាយនិងសង្គម” និង "ចលាចល” និង "សេដ្ឋកិច្ចជាតិ”។ ឃ្លាមួយចំនួននៅក្នុងប្រកាសនេះ មានភាពស្រពិចស្រពិល និងទូលាយពេក ហើយមិនស្របជាមួយលក្ខខណ្ឌតម្រូវ តាមមាត្រា១៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឡើយ។ ការរៀបចំបទប្បញ្ញត្តិ មិនមានភាពច្បាស់លាស់គ្រប់គ្រាន់ សម្រាប់បុគ្គលយកទៅកំណត់លើអាកប្បកិរិយារបស់ខ្លួនឯងណាស់។ ក៏ប៉ុន្តែ បញ្ហាដែលលើកឡើងគឺថាតើ គោលបំណងដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដូចជា ការបង្ការភាពចលាចល ការឲ្យអន្តរាយដល់សណ្ដាប់ធ្នាប់សាធារណៈ ឬស្ថេរភាពនយោបាយនិងសង្គមជាដើមនោះ តាមពិតទៅផ្តល់យុត្តិកម្មទៅលើការដាក់កំហិតសេរីភាពបញ្ចេញមតិដែរឬទេ។ ក្នុងន័យនេះ គណៈកម្មាធិការសិទ្ធិមនុស្ស បានចែងថា "គោលបំណងដែលមានធម្មានុភាពនៃការការពារ និងការពង្រឹងឯកភាពជាតិ ក្រោមកាលៈទេសៈនយោបាយដែលមានការលំបាក មិនអាចសម្រេចបានដោយការប៉ុនប៉ង បិទមាត់ការតស៊ូមតិរបស់ប្រជាធិបតេយ្យពហុបក្ស គោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សឡើយ” ។[121]

74. ដើម្បីឲ្យការបោះឆ្នោត មានលក្ខណៈពិតប្រាកដ រឹងមាំ និងសេរីនោះ ការជជែកវែកញែកជាសាធារណៈ មានសារៈសំខាន់ខ្លាំងណាស់។ ការជជែកវែកញែកគ្នានេះ ពឹង អាស្រ័យ ទៅលើការប្រាស្រ័យទាក់ទងដោយសេរីអំពីគំនិតនានាពាក់ព័ន្ធនឹងបញ្ហាសាធារណៈ និងនយោបាយ ដើម្បីឲ្យសាធារណជន បានទទួលព័ត៌មានពេញលេញពីគ្រប់ទស្សនៈ សូម្បីតែនៅពេលដែលគំនិតទស្សនៈទាំងនោះ អាចមានភាពផ្ទុយនិងមានភាពប្រទាញប្រទង់គ្នាក៏ដោយ។ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងព័ត៌មាន ជាមធ្យោបាយដ៏សំខាន់ខ្លាំងមួយដើម្បីសម្រេចតាមការប្រាថ្នាចង់បាននេះ។ ផ្ទុយមកវិញ ប្រកាសនេះ គឺជាការផ្ដល់នូវកម្រិតនៃឆន្ទានុសិទ្ធិទៅដល់អ្នកដែលពង្រឹងការអនុវត្ត ដែលនឹងធ្វើឲ្យមានការជ្រាតចូលដោយមិន

[120] CCPR/C/Rev.1/Add.7, para 25
[121] CCPR/C/GC/34, para 23

សមហេតុផល ទៅលើសិទ្ធិរបស់ជនដែលត្រូវគេចាត់ទុកជាជនគោលដៅ។

75. ការត្រួតត្រារបស់រដ្ឋាភិបាលនិងការឃ្លាំមើលតាមប្រព័ន្ធអ៊ីនធឺណែត គឺជាកត្តាដែលគួរឲ្យខ្លាចខ្លាំងសម្រាប់សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា។ អាជ្ញាធរកម្ពុជា បានបិទគេហទំព័រដែលមានប្រជាប្រិយភាពចំនួន១៧ ពីថ្ងៃទី២៧ ដល់ ២៩ ខែកក្កដា ក្នុងអំឡុងពេលបោះឆ្នោត។ គេហទំព័រទាំងនោះរួមមាន វិទ្យុសម្លេងសហរដ្ឋអាមេរិច ជាភាសាខ្មែរ វិទ្យុអាស៊ីសេរី ភាសាខ្មែរ និងកម្មវិធីវិទ្យុក្នុងស្រុកសម្លេងប្រជាធិបតេយ្យ។ មន្ត្រីជាន់ខ្ពស់មួយរូបនៅក្នុងក្រសួងព័ត៌មាន បានអះអាងថា គេហទំព័រទាំងនោះត្រូវបានជ្រើសរើស ដោយសារតែវាមានភាពអុជអាលនិងមាននិន្នាការនយោបាយខ្លាំង ដែលផ្តោតតែទៅលើការបោះឆ្នោត។[122]

## E. ការយាយីយាយីរំខានអ្នកការពារសិទ្ធិ

76. អវត្តមានរបស់គណបក្សសង្គ្រោះជាតិក្នុងការបោះឆ្នោត និងបទពិសោធន៍ពីមុនជាមួយ "បន្ទប់ស្ថានការណ៍" នៅក្នុងឆ្នាំ២០១៧ ក៏បាននាំឲ្យក្រុមសង្គមស៊ីវិលភាគច្រើនដកខ្លួនថយឆ្ងាយពីការបោះឆ្នោតឆ្នាំ២០១៨។ ក្រុមទាំងនេះ រួមមានអង្គការឃ្លាំមើលការបោះឆ្នោតសំខាន់ៗចំនួនបី គឺអង្គការខុមហ្វ្រែល[123] អង្គការនិចហ្វិច[124] និងអង្គការតម្លាភាពអន្តរជាតិ[125] ដែលបានថ្លែងថា ពួកគេនឹងមិនធ្វើការសង្កេតការណ៍បោះឆ្នោតទេ។ ក្រោយមក អង្គការខុមហ្វ្រែល បានបញ្ជាក់ថា អ្នកស្ម័គ្រចិត្តរបស់ខ្លួននឹងតាមដានស្ថានភាពសិទ្ធិមនុស្សនៅក្នុងបរិបទនៃការបោះឆ្នោត។

77. នៅថ្ងៃទី៥ ខែកក្កដា គណនី Facebook មួយបានបង្ហោះថា អង្គការខុមហ្វ្រែលកំពុងប្រើប្រាស់មូលនិធិសហភាពអឺរ៉ុប និងកំពុងជួលអតីតអ្នកគាំទ្រគណបក្សសង្គ្រោះជាតិដើម្បីបំផ្លាញការបោះឆ្នោត និងបង្កឲ្យមានចលាចល។[126] អង្គការខុមហ្វ្រែលបានបដិសេធការចោទប្រកាន់ទាំងនោះ ក្នុងសេចក្តីថ្លែងការណ៍មួយ ដែលបានបញ្ជាក់ច្បាស់ថា ទោះបីជាអង្គការមិនបានចុះឈ្មោះអ្នកសង្កេតការណ៍នៅ គ.ជ.ប និងមិនត្រៀមអ្នកសង្កេតការណ៍បោះឆ្នោតដូចក្នុងការបោះឆ្នោតមុនៗក៏ដោយ ក៏អង្គការនេះ នឹងត្រៀមអ្នកសង្កេតការណ៍ពលរដ្ឋចំនួន ៣០០នាក់ ទូទាំងប្រទេសដើម្បីតាមដានការប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ពលរដ្ឋ «ដោយរួមទាំង ការសម្រេចចិត្តរបស់ខ្លួនដោយគ្មានការបង្ខិតបង្ខំអំពី "ការទៅបោះឆ្នោត" និង "ការមិនទៅបោះឆ្នោត"» ។[127] អ្នករាយការណ៍ពិសេស បានទទួលព័ត៌មាន ដែលបង្ហាញថា ការបំភិតបំភ័យទៅលើអង្គការខុមហ្វ្រែលនិងអ្នកស្ម័គ្រចិត្ត មានការកើនឡើងភ្លាមៗបន្ទាប់ពីនោះមក។ មានការរាយការណ៍យ៉ាងហោចណាស់៣០ករណី ដែលអ្នកស្ម័គ្រចិត្ត ត្រូវបានគេសាកសួរ ឬព្រមានអំពីការចាប់ខ្លួន ដោយប៉ូលីសមូលដ្ឋាន។ ការបណ្តុះបណ្តាលដែលរៀបចំដោយអង្គការខុមហ្វ្រែលសម្រាប់អ្នកស្ម័គ្រចិត្ត បានក្លាយទៅជាគោលដៅជាក់លាក់មួយចំនួន គឺថា អ្នកស្ម័គ្រចិត្ត៥នាក់ ក្នុងចំណោម១២នាក់ ត្រូវបានប៉ូលីសនិងប៉ូ

[122] https://www.aljazeera.com/news/2018/07/cambodia-blocks-17-media-websites-vote- 180728103300267.html

[123] https://www.rfa.org/english/news/cambodia/comfrel-vote-05152018163110.html;

[124] https://www.phnompenhpost.com/national/nicfec-opts-not-observe-citing-fears-volunteers-election-watchdog-will-not-field-monitors

[125] http://www.ticambodia.org/download/ti-cambodia-press-release- 2018/?wpdmdl=2685&masterkey=5b29d4718d826

[126] https://www.facebook.com/229595330754816/posts/635167700197575/

[127] https://comfrel.org/wp-content/uploads/2018/07/741_Statement-on_-Denial-of-Allegation-on- COMFRELs-activities-in-2018-election_ENG-Final.pdf

លីសឃោជាមកជួប នៅក្នុងខេត្តកំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ ស្វាយរៀង និងបន្ទាយមានជ័យ។ មួយថ្ងៃមុនការបោះឆ្នោត អភិបាលខេត្តកំពង់ចាម បានអះអាងថា អង្គការខុមហ្វ្រែល បានជ្រើសរើសអ្នកសង្កេតការណ៍ដោយខុសច្បាប់។[128] ដោយមានការបារម្ភអំពីសន្តិសុខរបស់បុគ្គលនិងអ្នកស្ម័គ្រចិត្ត អង្គការខុមហ្វ្រែលបានសម្រេចចិត្ត ផ្អាកសកម្មភាពរបស់ខ្លួននៅថ្ងៃបោះឆ្នោត ។

78. ការបំភិតបំភ័យ មិនមែនកើតឡើងតែទៅលើអ្នកស្ម័គ្រចិត្តតែប៉ុណ្ណោះទេ។ បុគ្គលិកអង្គការខុមហ្វ្រែលក៏ត្រូវបានព្រមានអំពីការចាប់ខ្លួននៅក្នុងខេត្ត យ៉ាងហោចណាស់ចំនួន៤។ បន្ថែមពីលើការឃ្លាំមើលជាទៀងទាត់ដោយប៉ូលីសនិងអាជ្ញាធរមូលដ្ឋាន ការិយាល័យអង្គការខុមហ្វ្រែល នៅក្នុងខេត្តចំនួន៥ ក៏ទទួលបាន "ការមកទស្សនកិច្ចក្នុងលក្ខណៈរាក់ទាក់" ពីប៉ូលីសដែលចង់ដឹងអំពីព័ត៌មានលម្អិតអំពីសកម្មភាពរបស់ពួកគេ។ យោងតាមអង្គការខុមហ្វ្រែម ការបំភិតបំភ័យទៅលើបុគ្គលិកនិង "អ្នកសង្កេតការណ៍ពលរដ្ឋ" ស្ម័គ្រចិត្តមានលក្ខណៈរៀបចំនិងមានលក្ខណៈជាប្រព័ន្ធ។

## VI. ថ្ងៃបោះឆ្នោតនិងក្រោយថ្ងៃបោះឆ្នោត

79. គណបក្សចំនួន២០ បានចុះបញ្ជីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ ដែលចំនួននេះមានការកើនឡើងច្រើន បើធៀបនឹងការបោះឆ្នោតឆ្នាំ២០១៣ ដែលមានតែ៨គណបក្សប៉ុណ្ណោះ។ ដោយគណបក្សសង្គ្រោះជាតិត្រូវបានរំលាយហើយនោះ គណបក្សប្រឆាំងចម្បងៗសម្រាប់ការបោះឆ្នោតនេះ រួមមាន គណបក្សហ៊្វុនស៊ិនប៉ិច ដែលបានទទួលសន្លឹកឆ្នោតចំនួន ៣,៦៦% និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលបានទទួលសន្លឹកឆ្នោតចំនួន ១,០៣% ក្នុងឆ្នាំ២០១៣។ គណបក្ស៤ផ្សេងទៀតបានទទួលសន្លឹកឆ្នោតរួមគ្នាចំនួន ២,០៣% ក្នុងឆ្នាំ២០១៣។[129] គណបក្សចំនួន៦ផ្សេងទៀតបានចូលរួមក្នុងការបោះឆ្នោតឃុំសង្កាត់ក្នុងឆ្នាំ២០១៧ ប៉ុន្តែ មិនបានចូលរួមប្រជែងក្នុងការបោះឆ្នោតក្នុងឆ្នាំ២០១៣ ទេ ដែលនៅក្នុងចំណោមនោះ មានតែគណបក្សខ្មែររួបរួមជាតិមួយគត់ ទទួលបានតំណែងមេឃុំមួយ និងបានសន្លឹកឆ្នោត ១,១៣%។[130] គណបក្សចំនួន៥ផ្សេងទៀត បានទទួលសន្លឹកឆ្នោតរួមគ្នាចំនួន ០,៥៧% ក្នុងឆ្នាំ២០១៧។[131] គណបក្សចំនួន៦ ក្នុងការបោះឆ្នោតឆ្នាំ២០១៨ ជាគណបក្សដែលទើបចុះបញ្ជីថ្មី ក្រោយការបោះឆ្នោតមូលដ្ឋានឆ្នាំ២០១៧។[132] ជាការប្រៀបធៀប គណបក្សសង្គ្រោះជាតិ បានទទួលសន្លឹកឆ្នោត ៤៤% ក្នុងការបោះឆ្នោតឆ្នាំ២០១៣។ ជាសង្ខេប ក្នុងចំណោមគណបក្សប្រឆាំងទាំង ១៩ មិនមានគណបក្សនយោបាយណាមួយដែលមានកំណត់ត្រាអំពីការទាក់ទាញសន្លឹក

128 http://www.freshnewsasia.com/index.php/en/localnews/94240-2018-07-28-11-22-22.html

129 គណបក្សខ្មែរឈប់ក្រ (0.65%), គណបក្សសញ្ជាតិកម្ពុជា (0.58%), គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច (0.51%) និងគណបក្សសាធារណៈរដ្ឋប្រជាធិបតេយ្យ (0.29%)

130 គណបក្សចំនួន៧បានទទួលអាសនៈឃុំ/សង្កាត: CPP – 6503, CNRP – 5007, FUNCINPEC – 28, KNUP – 24, GDP – 5, LDP – 4, Beehive – 1

131 គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ (0.45%), គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (0.07%), គណបក្សយុវជនកម្ពុជា (0.02%), គណបក្ស ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា (0.02%), គណបក្សអំណាចខ្មែរ (0.01%);

132 គណបក្សរស្មីខេមរា, គណបក្សមាតុភូមិយើង, គណបក្សខ្មែរក្រោក, គណបក្សខ្មែរតែមួយ, គណបក្សឆន្ទៈខ្មែរ, គណបក្សពន្លឺថ្មី

ឆ្នោតដោយភាគរយខ្ពស់ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះទេ។ ប្រការនេះ ចោទជាសំណួរថា តើ វាមាន "ការប្រកួតប្រជែងពិតប្រាកដ" នៅក្នុងការបោះឆ្នោតនេះដែរឬទេ ដែលចំណុចនេះត្រូវបានគណៈកម្មាធិការសិទ្ធិមនុស្ស សង្កត់ធ្ងន់។ វាជាគួរឲ្យភ្ញាក់ផ្អើលដែរថា ក្នុងការបោះឆ្នោតសម័យទំនើបលើកដំបូងក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៣ មានគណបក្សចំនួន ២០ ដែលភាគច្រើនទើបបង្កើតថ្មី បានចូលរួមក្នុងការបោះឆ្នោត។ ២៥ឆ្នាំក្រោយមក វាជាការគួរឲ្យកត់សម្គាល់ដែលចំនួននេះ ត្រូវបានបន្លឺឡើងម្តងទៀត នៅក្នុងការបោះឆ្នោតឆ្នាំ ២០១៨។

80. ទោះបីមានបណ្តឹងមួយចំនួនអំពីគណបក្សប្រឆាំង ត្រូវបានរារាំងនិងវាយប្រហារនៅក្នុងអំឡុងពេលយុទ្ធនាការឃោសនាក៏ដោយ[133] ក៏ករណីបណ្តឹងទាំងនោះ មានសភាពមិនធ្ងន់ធ្ងរនិងតិចជាង បើប្រៀបធៀបនឹងការបោះឆ្នោតពីមុនៗកន្លងមក។ ចំណុចនេះ មានភាពស៊ីសង្វាក់ជាមួយនឹងការផ្លាស់ប្តូរយុទ្ធនាការឃោសនា ដែលការចូលរួមរបស់គណបក្សប្រឆាំងតូចៗ មានសារៈសំខាន់ក្នុងការធ្វើឲ្យវាមានលក្ខណៈជាការបោះឆ្នោតពហុបក្ស ទោះបីជាការដែលគណបក្សប្រជាជនកម្ពុជាឈ្នះ ជារឿងដែលជៀសមិនផុតក៏ដោយ។[134]

81. ការបោះឆ្នោត បានចាប់ផ្តើមនៅថ្ងៃទី២៩ ខែកក្កដា ពីម៉ោង ៧ព្រឹក ដល់ម៉ោង ៣រសៀល។ នៅថ្ងៃទី១៥ ខែសីហា គ.ជ.ប បានប្រកាសលទ្ធផលថា ចំនួនអ្នកមកបោះឆ្នោតជាផ្លូវការគឺ ៨៣,០២%, គណបក្សប្រជាជនកម្ពុជាទទួលបានសន្លឹកឆ្នោត៧៦,៨៥% នៃចំនួនសន្លឹកឆ្នោតបានការ, គណបក្សហ៊្វុនស៊ិនប៉ិច ឈរលំដាប់ទី២ បានទទួលសន្លឹកឆ្នោតចំនួន ៥,៨៩%, គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ឈរលំដាប់ទី៣ បានទទួលសន្លឹកឆ្នោតចំនួន ៤,៨៦%, និងគណបក្សឆន្ទៈខ្មែរ ឈរលំដាប់ទី៤ បានទទួលសន្លឹកឆ្នោតចំនួន ៣,៣៥%។[135] មានតែគណបក្សចំនួន២ផ្សេងទៀតប៉ុណ្ណោះដែលបានទទួលសន្លឹកឆ្នោតលើសពី ១% (គណបក្សខ្មែររួបរួមជាតិ, គណបក្សប្រជាធិបតេយ្យមូលដ្ឋាន)។ គណបក្សចំនួន១៤ផ្សេងទៀត បានសន្លឹកឆ្នោតសរុបរួមគ្នាចំនួន៦,៣៩%។ សន្លឹកឆ្នោតមិនបានការមានចំនួន៨,៥៥% នៃសន្លឹកឆ្នោតសរុប ដែលចំនួននេះ បានកើនឡើងលើសពីការបោះឆ្នោតឆ្នាំ២០១៣ និង២០១៧ រហូតដល់ទៅជាង ៥ដង។ គណបក្សប្រជាជនកម្ពុជា ទទួលអាសនៈទាំងអស់ក្នុងរដ្ឋសភា ចំនួន១២៥ អាសនា។

82. មានការទទួលបានបណ្តឹងអាចទុកចិត្តបាន ពីមនុស្សផ្សេងៗគ្នាដែលត្រូវបានបង្ខំឲ្យទៅបោះឆ្នោត បន្ទាប់ពីមានការគំរាមកំហែងឬការបំភិតបំភ័យនៅថ្ងៃបោះឆ្នោត ដោយរួមមានទាំងនៅភ្នំពេញ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្តរតនៈគីរី។ របាយការណ៍នេះ មានការលើកឡើងអំពីការទៅដល់ផ្ទះ និងការទូរសព្ទពីមន្ត្រីភូមិឃុំ ដែលបានធ្វើការគំរាមកំហែងដែលមានតាំងពី ការប្រឈមការលំបាកក្នុងការទទួលសេវាសាធារណៈ ការត្រូវបានគេរាយការណ៍ទៅអាជ្ញាធរឃុំ និងការដែលត្រូវគេចាត់ទុកជាអ្នកប្រឆាំង។

83. អ្នករាយការណ៍ពិសេស ក៏បានទទួលព័ត៌មានអំពីការផ្តល់លុយឲ្យទៅបោះឆ្នោតបន្ទាប់ពីទៅបោះឆ្នោតរួច។ យោងតាមរបាយការណ៍ អ្នកភូមិក្នុងខេត្តត្បូងឃ្មុំ កំពង់ចាម និងរតនគីរី បានទទួលប្រាក់ ២០.០០០ រៀល (៥ ដុល្លា) ពីអាជ្ញាធរភូមិនៅថ្ងៃទី២៩ និង៣០

[133] https://phnompenhpost.com/national/gdp-says-city-denying-it-billboard-placement
[134] https://www.khmertimeskh.com/50503101/pm-tells-officials-to-facilitate-campaigns/
[135] https://www.necelect.org.kh/khmer/content/3520

ខែកក្កដា បន្ទាប់ពីបោះឆ្នោតរួច ប្រសិនបើពួកគេបង្ហាញស្នាមទឹកខ្មៅនៅលើចង្អុលដៃជាភស្តុតាងថាបានទៅបោះឆ្នោត។ ក៏មានការរាយការណ៍អំពីមន្ត្រីភូមិឃុំ ទៅឆែកមើលម្រាមដៃដើម្បីកំណត់អត្តសញ្ញាណអ្នកដែលមិនទៅបោះឆ្នោត។ ក្នុងខេត្តរតនគីរី មានការអះអាងថាទាហាននិងប៉ូលីសនៅក្នុងភូមិ បានទៅឆែករកអ្នកដែលមិនទៅបោះឆ្នោត។ របាយការណ៍បែបនេះមួយចំនួន មានចុះផ្សាយដោយឡើងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។[136]

84. អ្នករាយការណ៍ពិសេស បានទទួលរបាយការណ៍ជាច្រើនថា នឹងមានការឆែកម្រាមដៃរបស់កម្មករ ពេលត្រឡប់ទៅធ្វើការវិញ ប៉ុន្តែ របាយការណ៍បែបនេះភាគច្រើន មិនមានភស្តុតាងសំអាងទេ។ ក៏ប៉ុន្តែ ក្នុងករណីមួយ ក្រុមហ៊ុនមួយនៅទីក្រុងភ្នំពេញ បានចេញលិខិតមួយកាលពីថ្ងៃទី២៦ ខែកក្កដា បញ្ជាក់ថា បុគ្គលិកកម្ពុជារូបណា ដែលមិនមានស្នាមទឹកខ្មៅនៅលើចង្អុលដៃទេនោះ នឹងត្រូវកាត់ប្រាក់ឈ្នួលចំនួនពីរថ្ងៃចេញពីប្រាក់ខែរបស់ពួកគេ។[137] បន្ទាប់ពីលិខិតនេះ បានលេចចេញនៅតាមបណ្ដាញសង្គមនិងទទួលការរិះគន់តាមប្រព័ន្ធអ៊ីនធឺណែតមក ក្រុមហ៊ុននោះបានសូមអភ័យទោសចំពោះកំហុសនៅក្នុងលិខិតនោះ ព្រមទាំងបានចេញលិខិតបញ្ជាក់ឡើងវិញនៅថ្ងៃបន្ទាប់ ដោយបានលើកឡើងថា នឹងមិនមានការកាត់ប្រាក់ឈ្នួលបែបនោះឡើយ។

85. អ្នករាយការណ៍ពិសេស បានឃើញរូបថតដែលបង្ហាញមន្ត្រីយោធានិងប៉ូលីស លើកម្រាមដៃដែលមានជ្រលក់ទឹកថ្នាំ នៅក្នុងការជង្ហែក្បួននានា មួយថ្ងៃក្រោយការបោះឆ្នោត។ រូបថតបែបនេះ ចំនួន២សន្លឹក អាចស្គាល់បានថាមកពីកងពលតូច៥៣ និងនាយកដ្ឋានប៉ូលីសក្រុងបាត់ដំបង។ ចំពោះរូបទីពីរ ស្នងការប៉ូលីសក្រុងបាត់ដំបង ប៉ាង ហៀង បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា ប៉ូលីសមិនត្រូវបានគេបំភិតបំភ័យទេ ហើយក៏មិនត្រូវគេបង្ខំឲ្យទៅបោះឆ្នោតដែរ ប៉ុន្តែ ពួកគេបង្ហាញម្រាមដៃជាប់ទឹកថ្នាំនេះ ដោយមោទនភាព។[138]

86. នៅក្នុងសេចក្ដីថ្លែងការណ៍មួយ ដែលរំលេចឡើងអំពីជោគជ័យនៃការបោះឆ្នោតនោះ ក្រសួងការបរទេស បានកត់សម្គាល់អំពី "បរិយាកាសពោរពេញដោយសន្តិភាពនិងរីករាយ" ដែលគណបក្សចំនួន២០ បានចូលរួមយុទ្ធនាការចំនួន២១ថ្ងៃ សម្រាប់ការបោះឆ្នោតដែលមាន "គណបក្សប្រឆាំងយ៉ាងពិតប្រាកដ" ។[139] បើយោងតាមក្រសួងការបរទេស អ្នកទៅបោះឆ្នោតដែលមានចំនួនច្រើន ជាការបង្ហាញអំពី "ជំនឿទុកចិត្តដ៏រឹងមាំរបស់ប្រជាពលរដ្ឋទៅលើដំណើរការបោះឆ្នោត"។ សេចក្ដីថ្លែងការណ៍នេះ ក៏បានសង្កត់ធ្ងន់ទៅលើវត្តមានអ្នកសង្កេតការណ៍អន្តរជាតិចំនួន ២២០នាក់ ភ្នាក់ងារគណបក្សនយោបាយចំនួន ៨៨.០០០នាក់[140] និង៨០.០០០នាក់ផ្សេងទៀត មកពីសមាគមនិងអង្គការនានាក្នុងប្រទេស។[141]

## VII. សេចក្ដីសន្និដ្ឋាន និង អនុសាសន៍

---

[136] https://www.rfa.org/khmer/news/politics/authority-traces-people-did-not-go-to-vote- 08012018070242.html

[137] https://www.facebook.com/FreeTEPvanny/photos/pcb.1099544213529057/1099540516862760

[138] https://www.rfa.org/english/news/cambodia/democracy-08012018165625.html

[139] https://www.mfaic.gov.kh/site/detail/19855.

[140] Of these, nearly 46,000 were from the CPP. FUNCINPEC and LDP had agents in approximately half of the 22,967 polling stations, see https://www.necelect.org.kh/khmer/sites/default/files/images- attachment/Party-Agent_Registration_report.jpg

[141] Nearly half of the observers are reported to be from the Union of Youth Federations of Cambodia, an organization headed by the Prime Minister’s son, also a CPP Parliamentarian,https://www.reuters.com/article/us-cambodia-election-monitors/election-monitoring-groups-in- cambodia-headed-by-pms-son-ambassador-idUSKBN1KA0FS

87. រហូតមកទល់នឹងការបោះឆ្នោតឆ្នាំ២០១៨នេះ ការបោះឆ្នោតជាតិ បានកែលម្អជាប្រចាំពាក់ព័ន្ធនឹងអនុលោមភាពជាមួយនឹងស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់នានាក្នុងប្រទេសកម្ពុជា ទោះបីជាមានការរំខាន ដោយសារតែការបំភិតបំភ័យអ្នកបោះឆ្នោត និងការវាយប្រហារគូបដិបក្ខនយោបាយក្នុងកម្រិតផ្សេងៗគ្នាក៏ដោយ។ ការបោះឆ្នោតជាតិឆ្នាំ២០១៣ និងការបោះឆ្នោតមូលដ្ឋានឆ្នាំ២០១៧ បានលើកកម្ពស់ការរំពឹងទុកមួយចំនួនដែលថា គណបក្សប្រឆាំងអាចនឹងដឹកនាំរដ្ឋាភិបាល តាមរយៈការបោះឆ្នោតដោយសន្តិវិធីដូចការប្រមើលឃើញនៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ។ ការបោះឆ្នោតឆ្នាំ២០១៨តំណាងឲ្យការចាកចេញពីគន្លងមុនៗ ដោយសារតែការរំលាយអតីតគណបក្សប្រឆាំងចម្បង និងការហាមឃាត់សមាជិកជាន់ខ្ពស់យ៉ាងច្រើនមកពីអតីតគណបក្សប្រឆាំង មិនឲ្យចូលរួមក្នុងសកម្មភាពនយោបាយចំនួន៥ឆ្នាំ។ ប្រការនេះ នាំឲ្យមានការចោទជាសំណួរយ៉ាងធ្ងន់ធ្ងរអំពីភាពពិតប្រាកដនៃការបោះឆ្នោតទាំងនេះ ដូចមានចែងនៅក្នុងមាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ការបែងចែកអាសនៈឡើងវិញពីអតីតគណបក្សប្រឆាំងទៅឲ្យគណបក្សផ្សេងទៀត ជាពិសេសនៅថ្នាក់ឃុំសង្កាត់ បានលើកឡើងនូវក្តីបារម្ភធ្ងន់ធ្ងរ អំពីការគោរពសិទ្ធិក្នុងការចូលរួមកិច្ចការសាធារណៈ តាមរយៈតំណាងដែលជ្រើសរើសដោយសេរី ដោយសារតែទង្វើនេះ បានដកហូតសិទ្ធិបោះឆ្នោតរបស់ប្រជាជនមួយចំណែកធំ ដោយរួមទាំងសិទ្ធិនៅក្នុងព្រឹទ្ធសភាទៀតផង។

88. ស្របគ្នានេះដែរ ការប្រើប្រាស់ច្បាប់ដើម្បីរឹតត្បិតការជជែកវែកញែកនិងការផ្តោតមុខសញ្ញាទៅលើប្រព័ន្ធផ្សព្វផ្សាយ គូបដិបក្ខនយោបាយ អង្គការសង្គមស៊ីវិល និងបុគ្គលនានាដោយរួមទាំងតាមរយៈការប្រើប្រាស់ការចោទប្រកាន់ព្រហ្មទណ្ឌផងនោះ បានធ្វើឲ្យលំហសម្រាប់ការជជែកវែកញែកបញ្ហានយោបាយ កាន់តែរួញតូចទៅ ដោយវាជាកត្តាដ៏សំខាន់មួយ សម្រាប់ការទទួលបានសិទ្ធិចូលរួមក្នុងការអនុវត្តកិច្ចការសាធារណៈ។ ការជជែកវែកញែកផ្នែកនយោបាយដែលមានពហុភាព គឺជាធាតុដ៏សំខាន់នៅក្នុងការបង្ហាញអំពីការប្រកួតប្រជែងពិតប្រាកដនៅក្នុងការបោះឆ្នោតណាក៏ដោយ។ អ្នករាយការណ៍ពិសេសរំលេចឡើងជាពិសេស អំពីការអំពាវនាវឲ្យធ្វើពហិកាចំពោះការបោះឆ្នោត ដែលនៅក្នុងការបោះឆ្នោតមិនមែនជាកាតព្វកិច្ច ការអំពាវនាវបែបនេះ ត្រូវបានគណៈកម្មាធិការសិទ្ធិមនុស្សទទួលស្គាល់ ជាការអនុវត្តសេរីភាពបញ្ចេញមតិដែលអនុញ្ញាតបាន។ របាយការណ៍អំពីការគំរាមកំហែងចំពោះអ្នកបោះឆ្នោត ប្រសិនបើពួកគេមិនទៅបោះឆ្នោតនោះ គឺជាក្តីបារម្ភជាពិសេស គឺថា ម្រាមដៃដែលមានប្រឡាក់ទឹកខ្មៅ ដែលពីមុន ជាសញ្ញានៃក្តីសង្ឃឹមនិងសេរីភាព បានប្រែក្លាយទៅជានិមិត្តរូបនៃការបង្ខិតបង្ខំទៅវិញ។

89. អ្នករាយការណ៍ពិសេស សូមជំរុញយ៉ាងខ្លាំងក្លា ចំពោះការពង្រីកលំហប្រជាធិបតេយ្យ ដើម្បីឲ្យអង្គការសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស និងសកម្មជននយោបាយ រួមទាំងសមាជិកអតីតគណបក្សសង្គ្រោះជាតិ អាចចូលរួមយ៉ាងសកម្មនិងចំហ ក្នុងការជជែកវែកញែកប្រកបដោយបរិយាប័ន្ន។ ដូច្នេះ លោកស្រី សូមអំពាវនាវជាពិសេសឲ្យមានការដោះលែងលោក កឹម សុខា ដោយគ្មានលក្ខខណ្ឌ, ដកបម្រាមលើសមាជិកជាន់ខ្ពស់អតីតគណបក្សសង្គ្រោះជាតិទាំង១១៨នាក់, តម្រឹមច្បាប់និងបទប្បញ្ញត្តិនានា ដូចជាច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីគណបក្សនយោបាយ បទប្បញ្ញត្តិស្តីពីការប្រមាថព្រះមហាក្សត្រ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិផ្សេងទៀត ឲ្យស្របតាមស្តង់ដារ

អន្តរជាតិ, កំណែទម្រង់ គ.ជ.ប ដើម្បីធានានិងរក្សាឯករាជភាពពីនយោបាយ, និង ការដក ចេញនូវវិធានការរឹតត្បឹតទៅលើសកម្មភាពអង្គការសង្គមស៊ីវិល ដូចជាសារាចរថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ ដែលតម្រូវឲ្យមានការជូនដំណឹងជាមុនសម្រាប់ការធ្វើសកម្មភាពរបស់អង្គការសង្គមស៊ីវិល។ វិធានការបែបទាំងនេះ គឺស្រប ទៅនឹងការប្តេជ្ញាចិត្តរបស់អាជ្ញាធរប្រទេសកម្ពុជា ចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៦ ដែលនឹងត្រូវពិនិត្យឡើងវិញនៅក្នុងវេទិកានយោបាយកម្រិតខ្ពស់ក្នុងឆ្នាំ២០១៩ដែរ។

៩០. អាទិភាពសំខាន់បំផុត គួរផ្តល់ទៅលើការកសាងវប្បធម៌មួយដែលការរិះគន់ក្នុងព្រំដែនសមហេតុផល មិនមែនត្រឹមតែត្រូវអនុញ្ញាតទេ គឺថែមទាំងត្រូវទទួលយក និងលើកទឹកចិត្ត ថាជាកត្តាសំខាន់ខានមិនបាន ដើម្បីរក្សាសន្តិភាពនិងការអភិវឌ្ឍន៍សម្រាប់រយៈពេលខ្លីនិងរយៈពេលវែង, វប្បធម៌មួយដែលការបែងចែកអំណាចរវាងស្ថាប័នផ្សេងគ្នារបស់រដ្ឋាភិបាល ក៏ដូចជាការបែងចែកឲ្យដាច់រវាងរដ្ឋនិងគណបក្សកាន់អំណាច ត្រូវបានគោរពនិងលើកតម្កើង, វប្បធម៌មួយដែលលទ្ធភាពនៃការផ្លាស់ប្តូររដ្ឋាភិបាលដោយសន្តិវិធីពីគណបក្សមួយទៅគណបក្សមួយទៀត តាមរយៈការបោះឆ្នោតពិតប្រាកដ ត្រូវបានទទួលយកជាក្រឹត្យក្រមជាជាងការតស៊ូដោយប្រើប្រាស់គ្រប់មធ្យោបាយផ្សេងពីនេះ។ ប្រសិនបើប្រទេសកម្ពុជានិងសហគមន៍អន្តរជាតិ មិនខិតខំព្យាយាមឲ្យបានខ្លាំងក្លាដើម្បីធ្វើឲ្យបានសម្រេចជោគជ័យទេនោះ ចក្ខុវិស័យនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស និងរដ្ឋធម្មនុញ្ញកម្ពុជា នឹងបន្តនៅតែជាក្តីសុបិនដ៏សែនឆ្ងាយមួយដដែល។

## ក្រាហ្វិក១៖ គណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភាពីឆ្នាំ១៩៩៣ ដល់២០១៨




| | |
|---|---|
| CNRP: គណបក្សសង្គ្រោះជាតិ | HRP: គណបក្សសិទ្ធិមនុស្ស |
| CPP: គណបក្សប្រជាជនកម្ពុជា | NRP: គណបក្សនរោត្តមរណឫទ្ធិ |
| FUN: គណបក្សហ្វុនស៊ិនប៉ិច | SRP: គណបក្សសមរង្ស៊ី |

**Source**: National Assembly Cambodia, http://www.national-assembly.org.kh/group-article/3.